UNITED NATIONS
OFFICE OF THE HIGH COMMISSIONER
FOR HUMAN RIGHTS IN CAMBODIA

NATIONS UNIES
BUREAU DU HAUT COMMISSAIRE
AUX DROITS DE L'HOMME AU CAMBODGE

អង្គការសហប្រជាជាតិ
ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

United Nations
Human Rights

# ការផ្តល់អនុសាសន៍លើបទបញ្ញត្តិមួយចំនួននៃសេចក្តីព្រាងក្រមព្រហ្មទណ្ឌ

អនុសាសន៍ខាងក្រោមនេះ រៀបរៀងដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ដើម្បីជួយសំរួលដល់ដំណើរការអនុម័តក្រមព្រហ្មទណ្ឌថ្មី។ អនុសាសន៍ទាំងនេះ ផ្តល់ជូនដោយផ្អែកជាសំខាន់លើកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិរបស់កម្ពុជា។ ការអនុម័តក្រមព្រហ្មទណ្ឌថ្មីនេះ ផ្តល់ឱកាសដ៏សំខាន់សំរាប់កម្ពុជាពង្រឹងការគោរពតាមកាតព្វកិច្ចអន្តរជាតិទាំងនេះរបស់ខ្លួន។

អនុសាសន៍ទាំងនេះ ផ្តោតទៅលើតែបទបញ្ញត្តិដែលអាចមានបញ្ហា។ នេះសបញ្ជាក់ថា មិនមែនអត្ថបទច្បាប់ទាំងមូល មិនត្រូវបានស្វាគមន៍នោះទេ - ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស មានជំនឿថា ក្រមព្រហ្មទណ្ឌនេះ តំណាងឲ្យជំហានជាវិជ្ជមាន និងមានសារសំខាន់មួយឆ្ពោះទៅមុខ ដើម្បីពង្រឹងប្រព័ន្ធច្បាប់នៅកម្ពុជា។

## ការឃ្លាំមើលការឃុំខ្លួនបណ្តោះអាសន្ន

មាត្រា២០៤នៃក្រមនីតិវិធីព្រហ្មទណ្ឌចែងថា " ការឃុំខ្លួនបណ្តោះអាសន្ន អាចអនុវត្តបាន តែក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ *ឬបទមជ្ឈិមដែលច្បាប់កំណត់ផ្តន្ទាទោសដាក់ពន្ធនាគារស្មើ ឬលើសពី១ឆ្នាំ* " (សេចក្តីបញ្ជាក់នេះមានថែមទៀត)។

រយៈពេលនៃការឃុំខ្លួនក្នុងពន្ធនាគារ ដែលមានបញ្ជាក់សំរាប់បទមជ្ឈិមខាងក្រោមនេះ ក្នុងមាត្រាទាំងឡាយនៃសេចក្តីព្រាងក្រមព្រហ្មទណ្ឌដែលរាយក្នុងបញ្ជីខាងក្រោម នឹងធ្វើឲ្យមាត្រា២០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ មិនអាចអនុវត្តបានឡើយ៖ តាមច្បាប់ វាមិនអាចធ្វើឲ្យប្រាកដប្រជាថា តើការឃុំខ្លួនបណ្តោះអាសន្ន អាចអនុវត្តទៅបានឬយ៉ាងណា ដោយសារតែគេមិនអាចដឹងបានថា តើការផ្តន្ទាទោសជាយថាហេតុ នឹងមានរយៈពេលលើសពី១ឆ្នាំ ឬយ៉ាងណានោះទេ។

| | | |
|---|---|---|
| មាត្រា២៣២ | បទគំរាមកំហែងដោយមានបញ្ជាឲ្យបំពេញលក្ខខណ្ឌអ្វីមួយ | ៦ខែ ទៅ២ឆ្នាំ |
| មាត្រា២៣៣ | បទគំរាមកំហែងថានឹងសម្លាប់ | ៦ខែ ទៅ២ឆ្នាំ |
| មាត្រា២៣៦ | បទបង្កឲ្យមានរបួសដោយចេតនា | ៦ខែ ទៅ២ឆ្នាំ |
| មាត្រា២៦១-២៦២ | បទប៉ះពាល់ដល់បូរណភាពនៃសាកសពនិងទីបញ្ចុះសព | ១ខែ ទៅ១ឆ្នាំ* |
| មាត្រា២៦៥ ដល់២៦៩ | បទបដិសេធក្នុងការផ្តល់ទ្រព្យសម្បត្តិ សេវា ឬការងារ | ១ខែ ទៅ១ឆ្នាំ* |
| មាត្រា២៧០ | បទបដិសេធក្នុងការផ្តល់សិទ្ធិដោយអ្នករាជការសាធារណដោយមូលហេតុនៃការរើសអើង | ៦ខែ ទៅ២ឆ្នាំ |
| មាត្រា២៧៤ | បទដាក់ឲ្យស្ថិតនៅក្នុងលក្ខខណ្ឌនៃការងារប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស | ១ខែ ទៅ១ឆ្នាំ* |
| មាត្រា២៧៨ និង២៧៩ | បទស៊ីសំណូកនៃនិយោជិត និងបទសូកប៉ាន់ដល់និយោជិត | ៦ខែ ទៅ២ឆ្នាំ |
| មាត្រា២៩៩ | បទរំលោភលើលំនៅឋាន | ១ខែ ទៅ១ឆ្នាំ* |
| មាត្រា៣០២ | បទប៉ះពាល់ដល់សិទ្ធិខាងរូបភាពនៃបុគ្គល | ១ខែ ទៅ១ឆ្នាំ* |
| មាត្រា៣១២ | បទប្តឹងបរិហារបង្កាច់កេរ្តិ៍ | ១ខែ ទៅ១ឆ្នាំ* |

No. 10, Street 302, Sangkat Boeng Keng Kang I, Khan Chamcar Mon, Phnom Penh Cambodia
Tel: +(855) 23 987 671 / 987 672 / 993 590 / 993 591 or 216 342 Fax: +(855) 23 212 579 or 213 587
E-mail: cambodia@ohchr.org Website: http://cambodia.ohchr.org

| | | |
|---|---|---|
| មាត្រា៣១៤ | ការប៉ះពាល់ដល់អាថ៌កំបាំងខាងវិជ្ជាជីវៈ | ១ខែ ទៅ១ឆ្នាំ* |
| មាត្រា៣១៧ និង៣១៨ | បទប៉ះពាល់ដល់ការឆ្លើយឆ្លងតាមលិខិត និងបទប៉ះពាល់ដល់ការសម្ងាត់នៃការសន្ទនាតាមទូរស័ព្ទ | ១ខែ ទៅ១ឆ្នាំ* |
| មាត្រា៣២៤ | បទបោះបង់គ្រួសារ - ការមិនបង់អាហារកិច្ច | ១ខែ ទៅ១ឆ្នាំ* |
| មាត្រា៣២៦ និង៣២៧ | បទមិនព្រមប្រគល់អនីតិជន និងបទដកយកអនីតិជន | ១ខែ ទៅ១ឆ្នាំ* |
| មាត្រា៣៤៣ | បទញុះញង់អនីតិជនឲ្យបរិភោគគ្រឿងស្រវឹង | ៦ខែ ទៅ២ឆ្នាំ |
| មាត្រា៣៤៤ | បទញុះញង់អនីតិជនឲ្យសុំទាន | ១ខែ ទៅ១ឆ្នាំ* |
| មាត្រា៣៤៧ | បទរំលោភអំណាចមេបា | ១ខែ ទៅ១ឆ្នាំ* |
| មាត្រា៣៥០ | បទទ្វេពន្ធភាព | ១ខែ ទៅ១ឆ្នាំ* |
| មាត្រា៣៥៦ | បទល្មើសលួច | ៦ខែ ទៅ៣ឆ្នាំ |
| មាត្រា៣៨៣ | បទរំលោភលើភាពល្ងង់ខ្លៅ ឬភាពទន់ខ្សោយ | ១ខែ ទៅ១ឆ្នាំ* |
| មាត្រា៣៨៧ | បទដេញថ្លៃមិនត្រឹមត្រូវ | ៦ខែ ទៅ២ឆ្នាំ |
| មាត្រា៣៩២ | អំពើរំលោភលើទំនុកចិត្ត | ៦ខែ ទៅ៣ឆ្នាំ |
| មាត្រា៣៩៧ | បទបង្វេរវត្ថុរឹបអូស ឬវត្ថុដាក់ធានា | ១ខែ ទៅ១ឆ្នាំ* |
| មាត្រា៤១០ | បទធ្វើឲ្យខូចខាតដោយចេតនា | ៦ខែ ទៅ២ឆ្នាំ |
| មាត្រា៤១៩ | បទធ្វើឲ្យខូចខាតផ្សេងទៀតដោយការខ្វះការប្រុងប្រយ័ត្ន ឬការមិនគោរពបទបញ្ជា | ១ខែ ទៅ១ឆ្នាំ* |
| មាត្រា៤២៧ | បទចូលទៅដល់ ឬស្ថិតនៅនឹងប្រព័ន្ធប្រព្រឹត្តិកម្មស្វ័យប្រវត្តិនៃទិន្នន័យ | ១ខែ ទៅ១ឆ្នាំ* |
| មាត្រា៤៧៣ | បទចូលដោយទុច្ចរិតក្នុងទីលានយោធា | ៦ខែ ទៅ១ឆ្នាំ* |
| មាត្រា៤៧៩ | បទលាតត្រដាងដោយចេតនា ឬអចេតនានូវការសម្ងាត់នៃការការពារជាតិ | ៦ខែ ទៅ២ឆ្នាំ |
| មាត្រា៤៩០ | បទកាន់កាប់ ឬដឹកជញ្ជូនអាវុធ ដោយគ្មានការអនុញ្ញាត | ៦ខែ ទៅ៣ឆ្នាំ |
| មាត្រា៤៩១ | បទបោះបង់អាវុធក្នុងទីកន្លែងសាធារណៈ | ៦ខែ ទៅ៣ឆ្នាំ |
| មាត្រា៤៩៥ | បទញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ | ៦ខែ ទៅ២ឆ្នាំ |
| មាត្រា៥០៤ | ស្ថានទម្ងន់ទោសនៃបទប្រឆាំងនឹងអ្នករាជការសាធារណៈ | ៦ខែ ទៅ១ឆ្នាំ* |
| មាត្រា៥២៩ | បទមិនប្តឹងបរិហារបទឧក្រិដ្ឋ និងការលើកលែង | ១ខែ ទៅ១ឆ្នាំ* |
| មាត្រា៥៣១ | បទលាក់បំបាំងសាកសព | ៦ខែ ទៅ២ឆ្នាំ |
| មាត្រា៥៣៤ | បទបំផ្លិចបំផ្លាញឯកសារ | ៦ខែ ទៅ២ឆ្នាំ |
| មាត្រា៥៣៦ | បទបំផ្លិចបំផ្លាញ ឬគៃបំបាត់វត្ថុដែលមានបិទស្លាកបោះត្រា | ៦ខែ ទៅ២ឆ្នាំ |
| មាត្រា៥៤៣ | បទរត់គេចខ្លួន | ៦ខែ ទៅ២ឆ្នាំ |
| មាត្រា៥៧១និង៥៧២ | បទប្រគល់ និងទទួលដោយខុសច្បាប់ពីជនជាប់ឃុំនូវទឹកប្រាក់ លិខិតឆ្លើយឆ្លង វត្ថុ ឬសារធាតុអ្វីមួយ | ១ខែ ទៅ១ឆ្នាំ* |
| មាត្រា៦០០ | បទបក្ខានុគ្រោះ | ៦ខែ ទៅ២ឆ្នាំ |
| មាត្រា៦១០-៦១៥ និង មាត្រា៦១៨-៦២០ | បទល្មើសផ្សេងៗទៀតទាក់ទងនឹងការក្លែងខ្លួនធ្វើជាមន្ត្រីសាធារណៈ | ១ខែ ទៅ១ឆ្នាំ* |
| មាត្រា៦៣២ និង៦៣៣ | បទសុំឲ្យផ្តល់ឯកសារដោយទុច្ចរិត និងបទផ្តល់សេចក្តីប្រកាសដោយភូតកុហក | ៦ខែ ទៅ២ឆ្នាំ |
| មាត្រា៦៣៤ - ៦៣៦ | បទផ្តល់លិខិតបញ្ជាក់មិនពិត បទក្លែងលិខិតបញ្ជាក់ និងបទប្រើប្រាស់លិខិតបញ្ជាក់មិនពិត ឬលិខិតបញ្ជាក់ក្លែងក្លាយ | ១ខែ ទៅ១ឆ្នាំ* |
| មាត្រា៦៥៨ | បទប្រើប្រាស់តែមប្រៃសណីយ៍ក្លែង | ១ខែ ទៅ១ឆ្នាំ* |
| មាត្រតា៦៦៣ - ៦៦៥ | បទក្លែងក្រដាសដែលមានក្បាលលិខិតផ្លូវការ បទប្រើប្រាស់ក្រដាសក្លែងដែលមានក្បាលលិខិតផ្លូវការ និងបទផលិតជាអាទ៍ក្រដាសពុម្ពដែលបង្កើតឱ្យមានការភ័ន្តច្រឡំ | ១ខែ ទៅ១ឆ្នាំ* |

ទន្ទឹមនឹងអាចជាចេតនាថា ជនណាមួយត្រូវចោទពីបទមជ្ឈិម មានទោសពី១ឆ្នាំ ឬលើសពី១ឆ្នាំឡើងទៅ អាចត្រូវបានឃុំខ្លួនបណ្តោះអាសន្ន ចេតនាបែបនេះ ទំនងជាមានភាពធ្ងន់ធ្ងរសំរាប់ជនត្រូវចោទដែលត្រូវរកឃើញពិរុទ្ធភាព ហើយដែលទីបំផុតទទួលទោសត្រឹមតែ១ខែ ឬ២ខែ ជាពិសេសដោយសារតែជនត្រូវចោទយ៉ាងច្រើន កំពុងត្រូវបានឃុំខ្លួនបណ្តោះអាសន្នលើសពី៦ខែ ដែលហួសរយៈពេលកំណត់ដោយច្បាប់សំរាប់បទមជ្ឈិម។ ជាលទ្ធផលសុទ្ធសាធគឺថា នៅក្នុងករណីជាច្រើន ទោសជាប់ពន្ធនាគារត្រឹមតែ២-៣ខែនឹងមិនមានន័យឡើយ។ លើសពីនេះទៅទៀត បញ្ហានេះស្ថិតនៅលើឆន្ទានុសិទ្ធិរបស់ចៅក្រម ហើយក្រមនេះផ្តល់គោលការណ៍ណែនាំមិនគ្រប់គ្រាន់ដល់ចៅក្រម ដើម្បីអនុញ្ញាតឲ្យប្រើឆន្ទានុសិទ្ធិនេះឲ្យបានសមស្រប។

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស សូមលើកជាអនុសាសន៍ថា នាពស្របគ្នានៃក្រមទាំងពីរនេះ គួរតែចែងឲ្យបានច្បាស់ ដើម្បីឲ្យចៅក្រមអាចសំរេចបានច្បាស់លាស់ នៅពេលកំណត់ការឃុំខ្លួនបណ្តោះអាសន្ន។

យើងខ្ញុំសូមលើកអនុសាសន៍ថា នាពខុសគ្នានៅក្នុងក្រមនេះ គួរតែញែកឲ្យដាច់ពីគ្នារវាងបទមជ្ឈិមស្រាលដែលអាចស្រូបទោសអតិបរិមា១ឆ្នាំ (បណ្តាមាត្រាមានគូសសញ្ញា * ខាងលើ) និងបទមជ្ឈិមធ្ងន់ធ្ងរជាង ទាក់ទងនឹងទោសលើសពី ១ឆ្នាំឡើងទៅ។ ក្រមនីតិវិធីព្រហ្មទណ្ឌ គួរតែចែងឲ្យច្បាស់ថា ការឃុំខ្លួនបណ្តោះអាសន្នត្រូវអនុវត្តចំពោះតែបទមជ្ឈិម ទាក់ទងនឹងទោសដែលមានរយៈពេលលើសពី ១ឆ្នាំប៉ុណ្ណោះ។

យើងខ្ញុំមានជំនឿថា បញ្ហានេះវាសំខាន់ពេកដែលមិនអាចទុកឲ្យក្រសួងយុត្តិធម៌ ចេញសេចក្តីណែនាំជាក្រោយ ហើយគួរតែចែងឲ្យបានច្បាស់លាស់តាមរយៈការធ្វើវិសោធនកម្មមួយចំពោះច្បាប់នេះ។

## ទោសអនុវត្តចំពោះអនីតិជន

មាត្រា៣៩នៃសេចក្តីព្រាងក្រមព្រហ្មទណ្ឌចែងថា " អនីតិជនដែលប្រព្រឹត្តបទល្មើស ជាកម្មវត្ថុនៃវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ។ ប៉ុន្តែ តុលាការ អាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌ ទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ <u>*ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ*</u> " (*សេចក្តីបញ្ជាក់ត្រូវបន្ថែម*)។

ក្រមនេះមិនមានចែងលក្ខណៈវិនិច្ឆ័យឲ្យបានជាក់លាក់ ដែលត្រូវសំរេចថាតើ " កាលៈទេសៈនៃបទល្មើស " ឬ " បុគ្គលិកលក្ខណៈរបស់អនីតិជន " នឹងត្រូវធ្វើយុត្តិកម្ម ដោយការប្រើទោសព្រហ្មទណ្ឌ ជាជាងប្រើវិធានការមួយផ្សេងក្នុងចំណោមវិធានការនានា ដែលបំរុងទុកសំរាប់អនីតិជន ឬយ៉ាងណានោះទេ។ ហេតុដូច្នេះ ហានិភ័យមានកំរិតខ្ពស់ ដែលទោសព្រហ្មទណ្ឌ តាមព្រឹត្តិហេតុ នឹងក្លាយជាបទដ្ឋាន សំរាប់អនីតិជន ដែលប្រព្រឹត្តបទល្មើស ដែលផ្ទុយទៅនឹងអនុសញ្ញាស្តីពីសិទ្ធិកុមារ ដែលមានចែងក្នុងមាត្រា៣៧ថា " <u>ការចាប់ខ្លួន ការឃុំខ្លួន ឬការដាក់ពន្ធនាគារកុមារ [...] ត្រូវប្រើសំរាប់តែជាវិធានការចុងក្រោយប៉ុណ្ណោះ</u> ហើយសំរាប់តែក្នុងរយៈពេលខ្លីបំផុតតាមតែអាចធ្វើបាន" ។

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សសូមលើកជាអនុសាសន៍ថា "កាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជន " គួរតែត្រូវកំណត់ឲ្យបានច្បាស់ថែមទៀតនៅក្នុងសេចក្តីព្រាងក្រមព្រហ្មទណ្ឌនេះ ដើម្បីផ្តល់ឲ្យចៅក្រមនូវគោលការណ៍ណែនាំដែលមានលក្ខណៈច្បាស់លាស់ជាងនេះស្តីអំពីពេលណាដែលទោសជាប់ពន្ធនាគារ អាចត្រូវបានកំណត់ជាពិសេសនោះ ដើម្បីធានាថា វិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ ដែលបានចែងក្នុងសេចក្តីព្រាងក្រមព្រហ្មទណ្ឌនេះ នៅតែស្ថិតនៅជាបទដ្ឋានដដែល។

## តុល្យភាពរវាងទោសឃុំខ្លួន និងទោសមិនត្រូវឃុំខ្លួន

ក្រោមបទបញ្ញត្តិព្រហ្មទណ្ឌអន្តរកាលអ៊ុនតាក់ ការផ្តន្ទាទោសទ្វេដងនៃការដាក់ពន្ធនាគារ ឬទោសពិន័យ ត្រូវបានចែងជាជំរើសផ្សេងៗ: អត្ថបទច្បាប់នេះប្រើតាមរូបមន្ត "និង/ឬ" ដើម្បីបញ្ជាក់ថាទោសពិន័យ ឬទោសគុក ឬទោសទាំងពីរ អាចត្រូវកំណត់។

ភាគច្រើននៃការផ្តន្ទាទោស ទាក់ទងនឹងទោសពិន័យ ក្នុងសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មីនេះ មានចែងអំពីរយៈ

ពេលនៃការជាប់ពន្ធនាគារ និងទោសពិន័យ មានន័យថា ទោសទាំងពីរនេះ តម្រូវឲ្យមានជាចាំបាច់នៅគ្រប់ករណីទាំងអស់។ ប្រការនេះ ធ្វើឲ្យប្រយោជន៍នៃទោសពិន័យជំនួសទោសឃុំខ្លួន ថយចុះយ៉ាងច្រើន។ បន្ថែមពីនេះទៅទៀត ដោយពិចារណាពីកំរិតនៃភាពក្រីក្រនៅប្រទេសកម្ពុជា ការផ្តន្ទាទោសបែបនេះអាចប៉ះពាលយ៉ាងធំធេងដល់កំនើនចំនួនអ្នកទោស ដោយសារតែជនជាប់ចោទ ដែលគ្មានលទ្ធភាពបង់ប្រាក់ពិន័យ ត្រូវផ្តន្ទាទោសឲ្យជាប់ពន្ធនាគារ។

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សសូមលើកជាអនុសាសន៍ថា ទោសពន្ធនាគារ និងទោសពិន័យ គួរតែឲ្យមានជាជំរើសណាមួយ ដោយដើរតាមគន្លងនៃការអនុវត្តកន្លងមក ដើម្បីអនុញ្ញាតឲ្យចៅក្រមមានឆន្ទានុសិទ្ធិជ្រើសរើស រវាងទោសជាប់ពន្ធនាគារ និងទោសពិន័យ ឬកំណត់ទោសទាំងពីរអាស្រ័យលើកាលៈទេសៈនៃករណី។ ហេតុដូច្នេះ អត្ថបទច្បាប់នេះ គួរតែត្រូវធ្វើវិសោធនកម្ម ដោយដាក់បញ្ចូលរូបមន្ត " និង/ឬ " តាមសតាពសមស្រប។

បន្ថែមទៅលើមូលទោសទាំងពីរ (ទោសជាប់ពន្ធនាគារ និងទោសពិន័យ - មាត្រា៤៣) ក្រមនេះ មានចែងទោសពីរទៀតជំនួសទោសគុក (ទោសបំរើការងារសហគមន៍ និងស្តីបន្ទោស - មាត្រា៧២ ដល់មាត្រា៧៦) និងបញ្ជីយ៉ាងវែងនៃទោសបន្ថែម ចំនួន១៩ទោសទៀត (មាត្រា៥៣ ដល់មាត្រា៧១) ដែលអាចបន្ថែមទៅលើមូលទោសបាន ឬក្នុងករណីខ្លះ អាចប្រើជំនួសមូលទោស (មាត្រា១០០)។

ភាពចង្អៀតណែននៃពន្ធនាគារ គឺស្ថិតក្នុងចំណោមបញ្ហាប្រឈមធំៗ ដែលអគ្គនាយកដ្ឋានពន្ធនាគារនៃក្រសួងមហាផ្ទៃ កំពុងជួបប្រទះសព្វថ្ងៃនេះ។ ភាពចង្អៀតណែននៃពន្ធនាគារ បណ្តាលមកពីសេចក្តីសំរេចទាំងឡាយ ដែលត្រូវធ្វើឡើងនៅតាមដំណាក់ការផ្សេងៗគ្នា នៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។ ក្រមព្រហ្មទណ្ឌមានឥទ្ធិពលដោយផ្ទាល់ទៅលើភាពចង្អៀតណែននៃពន្ធនាគារ ពីព្រោះក្រមនេះ ណែនាំដល់រាល់សេចក្តីសំរេច ទាក់ទងនឹងការជាប់ពន្ធនាគារថាជាការផ្តន្ទាទោស។

យោងតាមបញ្ញត្តិជាបទដ្ឋានអប្បបរមាសហប្រជាជាតិស្តីពីវិធានការមិនឃុំខ្លួន (" វិធានក្រុងតូក្យូ ") ឆ្នាំ១៩៩០ វិធានការមិនឃុំខ្លួនទាំងឡាយ គួរត្រូវប្រើប្រាស់ស្របតាមគោលការណ៍អន្តរាគមន៍ជាអប្បបរមា (គោលការណ៍ទី២.៦)។

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស សូមលើកជាអនុសាសន៍ថា ភាគច្រើននៃទោសបន្ថែមគួរតែឲ្យមានជាជំរើសផ្សេង ជំនួសការដាក់ពន្ធនាគារ។ ប្រការនេះ នឹងផ្តល់ជំរើសមិនឃុំខ្លួនច្រើនយ៉ាង ដែលគួរតែគិតគូរដល់សេចក្តីត្រូវការក្នុងការធ្វើឲ្យជនល្មើសស្តារនីតិសម្បទាឡើងវិញ និងការលំបាកនានា ក្នុងការរៀបចំកម្មវិធីស្តារនីតិសម្បទានៅពន្ធនាគារ ជាពិសេសនៅតាមពន្ធនាគារដែលមានលក្ខណៈចង្អៀតណែន។

## អនុភាពនៃការមិនរាងចាល

ការប្រព្រឹត្តបទឧក្រិដ្ឋថ្មីមួយក្រោយពីត្រូវបានផ្តន្ទាទោសជាស្ថាពររួចហើយពីបទឧក្រិដ្ឋមួយលើកដំបូង ទំនងជាមានទោសធ្ងន់ធ្ងរជាង ការប្រព្រឹត្តបទឧក្រិដ្ឋថ្មីមួយ ក្រោយពីត្រូវបានផ្តន្ទាទោសជាស្ថាពររួចហើយពីបទមជ្ឈិមមួយលើកដំបូង។ ប៉ុន្តែមាត្រា៨៨ ដែលទាក់ទងនឹង " ការមិនរាងចាលក្នុងបទឧក្រិដ្ឋ " និងមាត្រា៨៧ ដែលទាក់ទងនិង " ការមិនរាងចាលក្នុងបទឧក្រិដ្ឋ បន្ទាប់ពីការផ្តន្ទាទោសពីបទមជ្ឈិម " ផ្តល់អានុភាពដូចគ្នានៃការមិនរាងចាលនេះ ពោលគឺអតិបរមានៃទោសដាក់ពន្ធនាគារចំពោះបទឧក្រិដ្ឋថ្មី មិនលើសពី២០ឆ្នាំទេ អតិបរមានេះ ត្រូវទ្វេឡើង ហើយអតិបរមានៃទោសដាក់ពន្ធនាគារចំពោះបទឧក្រិដ្ឋថ្មីមានរយៈពេល៣០ឆ្នាំ អតិបរមានៃទោស គឺដាក់ពន្ធនាគារអស់មួយជីវិត។

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស សូមលើកជាអនុសាសន៍ថា មាត្រា៨៨ និងមាត្រា៨៧ គួរតែឆ្លុះបញ្ចាំងឲ្យបានល្អជាងនេះ ពីភាពខុសគ្នាក្នុងកំរិតធ្ងន់ធ្ងររវាងការមិនរាងចាលនៃបទល្មើសទាំងពីរប្រភេទនេះ។

## ការហាមឃាត់អំពើទារុណកម្ម

**មាត្រា២១០៖** ចាត់ទុកទារុណកម្ម គឺជាបទល្មើសព្រហ្មទណ្ឌដាច់ដោយឡែកមួយ។ នេះជាជំហានវិជ្ជមានមួយ ស្របតាមកាតព្វកិច្ចអន្តរជាតិរបស់កម្ពុជា ក្រោមអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ព្រមទាំងការហាមប្រាមការធ្វើទារុណកម្ម តាមមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញផង។

ក៏ប៉ុន្តែបទបញ្ញត្តិនេះ មិនមាននិយមន័យជាក់លាស់ ពន្យល់ឲ្យបានច្បាស់លាស់ពីទារុណកម្ម តាមពាក្យពេជន៍ច្បាប់ទេ។ បញ្ហានេះ អាចនាំឲ្យមានការយល់ច្រឡំ ឬមានន័យមិនច្បាស់លាស់។

កម្ពុជាដែលជារដ្ឋភាគីមួយនៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម ត្រូវអនុវត្តស្របតាមទស្សនៈនៃទារុណកម្ម ដូចមានចែងក្នុងអនុសញ្ញា។ មាត្រា១ នៃអនុសញ្ញា មានចែងពីនិយមន័យតាមផ្លូវច្បាប់ ដែលមានន័យ*ជាអប្បបរមា*នៃអ្វីដែលគួរតែត្រូវបានចាត់ទុកថាជាទារុណកម្ម។ និយមន័យផ្សេងពីនេះដែលមានន័យទូលាយជាង ក៏អាចទទួលយកបានដែរ តែត្រូវស្ថិតនៅជុំវិញទស្សនៈនៃទារុណកម្ម ដែលកំណត់ន័យដោយអនុសញ្ញា នៅក្នុងក្របខ័ណ្ឌនៃនិយមន័យដែលទូលាយជាងនេះ។

កាលពីខែមីនា ឆ្នាំ២០០៤ គណៈកម្មាធិការអង្គការសហប្រជាជាតិប្រឆាំងនឹងការធ្វើទារុណកម្ម នៅហ្សឺណែវ បានស្នើសុំជាពិសេសដល់រាជរដ្ឋាភិបាលកម្ពុជា *ឲ្យដាក់បញ្ចូលទៅក្នុងច្បាប់ជាតិរបស់ខ្លួននូវនិយមន័យនៃទារុណកម្ម ដូចមានចែងក្នុងមាត្រា១ នៃអនុសញ្ញា ហើយកំណត់ចរិកលក្ខណៈអំពើនានានៃទារុណកម្ម ថាជាបទល្មើសជាក់លាក់ដែលត្រូវផ្តន្ទាទោសឲ្យបានសមរម្យបំផុត។*[1] ការអនុម័តក្រមព្រហ្មទណ្ឌ ផ្តល់ឱកាសឲ្យរដ្ឋាភិបាលអនុវត្តតាមសំណើសុំនេះ ក៏ប៉ុន្តែប្រសិនបើនិយមន័យទារុណកម្ម មិនត្រូវបានដាក់បញ្ចូលទៅក្នុងបទបញ្ញត្តិនៃក្រមនេះទេ វានឹងមិនមែនជាការឆ្លើយតបពេញលេញមួយនោះទេ។ កម្ពុជា កំពុងស្ថិតនៅក្នុងដំណើរការរៀបចំរបាយការណ៍បន្ទាប់របស់ខ្លួន ដាក់ជូនគណៈកម្មាធិការប្រឆាំងទារុណកម្ម ហើយគណៈកម្មា ធិការនេះសង្ឃឹមថា នឹងឃើញកម្ពុជា អនុវត្តតាមអនុសាសន៍ដែលគណៈកម្មាធិការបានធ្វើ កាលពីឆ្នាំ២០០៤។

ការិយាល័យខ្ពត្តមស្នងការសិទ្ធិមនុស្ស សូមផ្តល់អនុសាសន៍ថា គួរតែដាក់បញ្ចូលនិយមន័យតាមផ្លូវច្បាប់ នៅក្នុងបទបញ្ញត្តិនៃក្រមនេះ យ៉ាងហោចណាស់ឲ្យមានន័យទូលាយដូចនិយមន័យនៅក្នុងមាត្រា១នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម។ សូមមើលឯកសារសំរង់ដូចមានភ្ជាប់ជូនមកជាមួយ។

**មាត្រា២១១** ចែងពីជនរងគ្រោះដោយទារុណកម្មជាបីប្រភេទផ្សេងៗគ្នា ទាមទារឲ្យមានការការពារពិសេស ដូចជា បុគ្គលដែលជាពិសេសទន់ខ្សោយដោយមូលហេតុអាយុនៃបុគ្គលនោះ ស្ត្រីមានគ៌ភ និងអ្នកជំងឺ។

ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស សូមស្វាគមន៍ចំពោះបទបញ្ញត្តិនេះ ប្រសិនបើបទបញ្ញត្តិនេះ ចែងឲ្យច្បាស់ជាងនេះថា វាក៏អនុវត្តចំពោះកុមារផងដែរ(បុគ្គលដែលមានអាយុក្រោម១៨ឆ្នាំ) ដោយសារតែមាត្រា៣៧(ក) នៃអនុសញ្ញាសិទ្ធិកុមារ ហាមឃាត់ជាពិសេសការធ្វើទារុណកម្មកុមារ(ដូចមានឯកសារភ្ជាប់ជូនជាមួយ)។ គួរឲ្យកត់សំគាល់ផងដែរថា គណៈកម្មាធិការសិទ្ធិកុមារនៅហ្សឺណែវ បានទាញភ្ជាប់គ្នា រវាងការធ្វើទារុណកម្ម និងការប្រព្រឹត្ត ឬទណ្ឌកម្មដទៃទៀតដែលឃោរឃៅ អមនុស្សធម៌ និងបន្ថោកបន្ទាប ជាមួយនឹងការដាក់ទណ្ឌកម្មខាងរាងកាយ។ នៅក្នុងករណីនេះ យើងក៏គួរតែពិចារណាដាក់បញ្ចូលការវាយដំ ឬការដាក់ទណ្ឌកម្មលើរាងកាយ ថាជាផ្នែកមួយនៃស្ថានទម្ងន់ទោសនៅក្នុងមាត្រា៣៣៧ មាត្រា៣៣៩ និងមាត្រា៣៤៧ នៃក្រមព្រហ្មទណ្ឌ។

**មាត្រា២១២** កំណត់ប្រភេទ៤យ៉ាងនៃទារុណកម្ម ឬអំពើឃោរឃៅ ដោយមានគោលបំណង ឬគោលដៅច្បាស់លាស់ ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១០ឆ្នាំ ទៅ២០ឆ្នាំៈ

- ទារុណកម្មដែលមានគោលដៅទប់ស្កាត់នរណាម្នាក់មិនឲ្យដាក់ពាក្យបណ្តឹង
- ទារុណកម្មដែលមានគោលដៅដាក់ទណ្ឌកម្មនរណាម្នាក់ដោយសារតែបានដាក់ពាក្យបណ្តឹង
- ទារុណកម្មដែលមានគោលដៅបង្ការសាក្សីមិនឲ្យផ្តល់ភស្តុតាង
- ទារុណកម្មដែលមានគោលដៅដាក់ទណ្ឌកម្មសាក្សីដោយសារតែបានផ្តល់ភស្តុតាង

ការិយាល័យយើងជឿជាក់ថា នៅពេលដែលអំពើទាំងនេះសក្តិសមនឹងត្រូវផ្តន្ទាទោស បញ្ជីខាងលើនេះ នៅមិនទាន់ពេញលេញនៅឡើយទេ។ និយាយដោយឡែក បទបញ្ញត្តិនេះ មិនមានចែងពីមូលហេតុចំបងនៃទារុណកម្មនៅកម្ពុជាសព្វថ្ងៃនេះទេៈ ទារុណកម្មដែលប្រព្រឹត្តដោយនគរបាល ឬមន្ត្រីប្រតិបត្តិច្បាប់ដទៃទៀត ដើម្បីជំរិតយកចំលើយ

---

[1] CAT/C/CR/31/7 at para. 7.

សារភាព នៅក្នុងបរិបទនៃការស៊ើបអង្កេតរបស់នគរបាល។ សេណារីយ៉ូមួយទៀត គឺទារុណកម្មដែលមានគោលដៅជំរិតទារប្រាក់ ឬផលប្រយោជន៍ផ្សេងទៀតពីបុគ្គល។

ការិយាល័យសូមផ្តល់អនុសាសន៍ថា មាត្រា២១២គួរតែពង្រីកអត្ថន័យដោយដាក់បញ្ចូល:

- ទារុណកម្មដែលមានគោលដៅបង្ខំនរណាម្នាក់ឲ្យឆ្លើយសារភាពពីពិរុទ្ធភាពចំពោះបទល្មើស ដោយមិនគិតថាតើ ម្នាក់នោះ តាមពិត មានពិរុទ្ធភាព ឬអត់។
- ទារុណកម្មដែលមានគោលដៅជំរិតទារប្រាក់ ឬផលប្រយោជន៍ផ្សេងទៀតពីបុគ្គល។

តាមរយៈការកែប្រែនេះ បទបញ្ញត្តិនេះ នឹងជួយពង្រឹងយ៉ាងខ្លាំង ដល់ការបង្ការប្រឆាំងនឹងការធ្វើទារុណកម្ម នៅក្នុងច្បាប់កម្ពុជា ដែលត្រូវបានហាមឃាត់រួចហើយតាមរយៈមាត្រា៣៨នៃរដ្ឋធម្មនុញ្ញ។

រាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងបណ្តាឆ្នាំថ្មីៗនេះ ដើម្បីកែលំអស្ថានភាពស្តីពីការបង្ការទារុណកម្មនៅកម្ពុជា ហើយអ្វីដែលគួរឲ្យកត់សំគាល់បំផុតនោះ គឺតាមរយៈការផ្តល់សច្ចាប័នលើពិធីសារបន្ថែម នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម កាលពីខែមករា ឆ្នាំ២០០៧។ នៅក្នុងសេចក្តីថ្លែងហេតុដែលសម្តេចនាយករដ្ឋមន្ត្រី បានដាក់សេចក្តីព្រាងច្បាប់ ដើម្បីផ្តល់សច្ចាប័នលើពិធីសារនេះកាលពីខែកញ្ញា ឆ្នាំ២០០៦ លោកបានមានប្រសាសន៍ខ្លាំងៗពីតំរូវការប្រយុទ្ធប្រឆាំងនឹងការធ្វើទារុណកម្ម។ ដូច្នេះ ការិយាល័យយើង ប្រាកដណាស់ថា សមាជិកនៃគណៈបក្សនយោបាយទាំងអស់ នឹងគាំទ្រឲ្យមានបទបញ្ញត្តិខ្លាំងមួយ ប្រឆាំងនឹងការធ្វើទារុណកម្ម នៅក្នុងក្រមព្រហ្មទណ្ឌថ្មីនេះ ស្របទៅតាមបទដ្ឋានអន្តរជាតិ។

ក្នុងខែធ្នូ ឆ្នាំនេះ មន្ត្រីជាន់ខ្ពស់សហប្រជាជាតិមួយក្រុម នឹងមកទស្សនកិច្ចនៅកម្ពុជា ដើម្បីត្រួតពិនិត្យមើលពន្ធនាគារនៅទូទាំងប្រទេសកម្ពុជា និងពិនិត្យមើលវិធានការអ្វីខ្លះ ដែលរាជរដ្ឋាភិបាលបានធ្វើ ដើម្បីប្រយុទ្ធប្រឆាំងនឹងទារុណកម្ម។ នេះជាការប្រពៃណាស់ ប្រសិនបើរាជរដ្ឋាភិបាលអាចនិយាយ ទៅកាន់ក្រុមមន្ត្រីសហប្រជាជាតិទាំងនោះថា ក្រមព្រហ្មទណ្ឌថ្មី ត្រូវបានអនុម័តដោយមានបទបញ្ញត្តិរឹងមាំ ប្រឆាំងនឹងទារុណកម្ម។

## ការការពារកុមារពីការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ

មាត្រា៣៣០ មាត្រា៣៣១ និងមាត្រា៣៣៣ មានគោលបំណងការពារកុមារពីការជួញដូរមនុស្ស។ មាត្រា៣៣០ ដោះស្រាយចំពោះបទញុះញង់ឲ្យបោះបង់ទារក ក្នុងគោលដៅចង់បានកម្រៃ។ មាត្រា៣៣១ ដាក់ឲ្យនៅក្រៅច្បាប់ ចំពោះអំពើជាអន្តរការីរវាងអ្នកអ្នកសុំកូន និងអ្នកបោះបង់កូនក្នុងគោលដៅចង់បានកម្រៃ។ មាត្រា៣៣៣ ហាមឃាត់ពីបទជំនួស ក្លែង ឬលាក់បំបាំងអត្តិភាពនៃទារក កាលបើអំពើនេះនាំឲ្យមានការក្លែងបន្លំអាត្រានុកូលដ្ឋាន។ មាត្រានីមួយៗទាំងនេះ សុទ្ធតែបានកំណត់ទោសស្រាលពេក បើប្រៀបធៀបនឹងភាពធ្ងន់ធ្ងរនៃបទល្មើស ពោលគឺកំរិតទោសគ្រាន់តែចាប់ពី១ខែ ដល់៦ខែ ហើយពិន័យជាប្រាក់ពី១០០០០០រៀល ទៅ១លានរៀលតែប៉ុណ្ណោះ។

ការជួញដូរកុមារ គឺជាការអនុវត្តន៍ដែលអាចរកប្រយោជន៍បានយ៉ាងសំបើម ជាមួយនឹងការរកកម្រៃជាសក្តានុពលរាប់ពាន់ដុល្លា។ ដើម្បីឲ្យបញ្ញត្តិព្រហ្មទណ្ឌទាំងនេះ មានចែងពីវិធានការប្រកបដោយប្រសិទ្ធភាព និងគួរឲ្យញញើតប្រឆាំងនឹងសកម្មភាពព្រហ្មទណ្ឌដែលអាចរកកម្រៃបាន ការផ្តន្ទាទោសត្រូវតែសមាមាត្រនឹងអំពើបែបនេះ។

ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស សូមផ្តល់អនុសាសន៍ថា ទោសអនុវត្តចំពោះបទល្មើសទាំងនេះ ដែលមានចែងក្នុងមាត្រា៣៣០ មាត្រា៣៣១ និងមាត្រា៣៣៣ គួរតែបង្កើនទោសឲ្យបានធ្ងន់ធ្ងរ ដើម្បីឆ្លុះបញ្ចាំងឲ្យកាន់តែច្បាស់ ពីភាពធ្ងន់ធ្ងរនៃបទល្មើសទាំងនេះ និងបង្ហាញពីភាពគួរឲ្យញញើតពិតប្រាកដៗ។

ចាប់តាំងពីការអនុម័តច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ កាលពីឆ្នាំ២០០៨មក វាលេចចេញច្បាស់ថា មានចន្លោះប្រហោងខ្លះ ក្នុងការការពារកុមារប្រឆាំងនឹងការធ្វើអាជីវកម្មកុមារ ក្នុងបំណងសំរាប់ការផលិត និងការប្រើប្រាស់រូបភាព-សំភារៈអាសអាភាស ដែលទាក់ទងនឹងកុមារ។ និយាយដោយឡែក មាត្រា៤១នៃច្បាប់នេះ អនុវត្តចំពោះតែការចែកចាយ ការលក់ ការជួល ការដាក់តាំង ការបញ្ចាំង ឬការបង្ហាញរូបភាព-សំភារៈអាសអាភាស *នៅទីសាធារណៈ* ប៉ុណ្ណោះ។ នេះមានន័យថា សកម្មភាពដដែលដូចខាងលើនេះ ដើម្បីផ្សព្វផ្សាយរូបភាព-សំភារៈអាសអាភាសកុមារ *នៅទីកន្លែងឯកជន* នឹងមិនត្រូវទទួលការផ្តន្ទាទោសទេ។

គួរឲ្យកត់សំគាល់ផងដែរថា តាមមាត្រា៣ នៃពិធីសារបន្ថែមលើអនុសញ្ញាស្តីពីសិទ្ធិកុមារពាក់ព័ន្ធនឹងការលក់កុមារ ពេស្យាកម្មកុមារ និងរូបភាព-សំភារៈអាសអាភាសកុមារ ដែលកម្ពុជាបានផ្តល់សច្ចាប័ន កាលពីថ្ងៃទី៣០ សីហា ២០០២ រាជរដ្ឋាភិបាល ត្រូវធានាថា ក្រមព្រហ្មទណ្ឌថ្មីនេះ ត្រូវហាមឃាត់រូបភាព-សំភារៈអាសអាភាសកុមារ ទោះជានៅទីសាធារណៈ ឬកន្លែងឯកជនក៏ដោយ។

ការិយាល័យសូមផ្តល់អនុសាសន៍ថា គួរតែដាក់បញ្ចូលបទបញ្ញត្តិមួយទៀត បន្ទាប់ពីមាត្រា៣៤១ និងមាត្រា៣៤២ នៃក្រមព្រហ្មទណ្ឌថ្មីនេះ ទាក់ទងនឹងអំពើបៀតបៀនកេរ្តិ៍ខ្មាស់កុមារ ដោយធ្វើវាឲ្យទៅជាបទល្មើសព្រហ្មទណ្ឌមួយចំពោះការចែកចាយ ការលក់ ការជួល ការដាក់តាំង ការបញ្ចាំង ឬការបង្ហាញរូបភាព-សំភារៈអាសអាភាសកុមារ <u>ទោះជានៅទីសាធារណៈ ឬកន្លែងឯកជនក៏ដោយ</u>។

ការិយាល័យសូមផ្តល់អនុសាសន៍បន្ថែមទៀតថារដ្ឋសភាគួរតែពិគ្រោះយោបល់លើបញ្ហានេះជាមួយក្រុមប្រឹក្សាជាតិដើម្បីកុមារលើបញ្ហានេះ។

## បទបញ្ញត្តិនានាទាក់ទងនឹងការធ្វើឲ្យមានតុល្យភាពរវាង សេរីភាពក្នុងការបញ្ចេញមតិ និងការការពារកិត្តិស័ព្ទ

គន្លឹទី២ នៃសេចក្តីព្រាងក្រមព្រហ្មទណ្ឌ មានបញ្ចូលជំពូកដែលមានគោលដៅការពារទល់នឹងការប៉ះពាល់ដល់បុគ្គលិកលក្ខណៈរបស់បុគ្គល រាប់ទាំងកិត្តិស័ព្ទផង។ បទបញ្ញត្តិទាំងនេះ អាចជាការរួមចំណែកយ៉ាងសំខាន់ ក្នុងការធានាការពារសិទ្ធិរបស់បុគ្គលគ្រប់រូប ឲ្យរួចចាកផុតពីការវាយប្រហារដោយខុសច្បាប់ទៅលើកិត្តិយស និងកិត្តិស័ព្ទរបស់ពួកគេ ស្របតាមមាត្រា១៧ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ ទោះបីជាយ៉ាងណាក៏ដោយ កិច្ចការពារនេះ ត្រូវមានតុល្យភាពនឹងសិទ្ធិដ៏សំខាន់ស្មើភាពគ្នា ដល់សេរីភាពនៃការបញ្ចេញមតិ និងយោបល់ស្របតាមមាត្រា១៩នៃកតិកាដូចគ្នានេះ។

សេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី មានសក្តានុពលរិតត្បិត ទៅលើសេរីភាពនៃការបញ្ចេញមតិច្រើនជាងបទបញ្ញត្តិទាំងឡាយនៃច្បាប់ព្រហ្មទណ្ឌអន្តរកាលអ៊ុនតាក់ដែលធ្លាប់បានក្លាយជាកម្មវត្ថុសំរាប់ការពិភាក្សាយ៉ាងច្រើនរួចមកហើយនៅប្រទេសកម្ពុជា។ បទបញ្ញត្តិទាំងឡាយនៃច្បាប់ព្រហ្មទណ្ឌអន្តរកាលអ៊ុនតាក់ បានផ្តន្ទាទោសចំពោះការរិតត្បិតទៅលើសេរីភាពនៃការបញ្ចេញមតិ តាមរយៈបទបញ្ញត្តិនានាទាក់ទងនឹងបទល្មើសព្រហ្មទណ្ឌបរិហារកេរ្តិ៍ ការផ្សាយព័ត៌មានមិនពិត និងការញុះញង់។ ក្រមព្រហ្មទណ្ឌថ្មីនេះ រក្សាទុកបទល្មើសព្រហ្មទណ្ឌបរិហារកេរ្តិ៍ដដែល និងបង្កើតបទល្មើសព្រហ្មទណ្ឌផ្សេងៗបន្ថែមទៀត ដោយមានសក្តានុពលកាត់បន្ថយសេរីភាពនៃការបញ្ចេញមតិ រួមមាន៖

-បទក្លែងព័ត៌មាន (មាត្រា៤២៥)
-បទជេរប្រមាថជាសាធារណៈ (មាត្រា៣០៧)
-បទប្តឹងបរិហារបង្កាច់កេរ្តិ៍ (មាត្រា៣១១)
-បទផ្សព្វផ្សាយនូវការអត្ថាធិប្បាយ ដើម្បីធ្វើសំពាធលើយុត្តាធិការ (មាត្រា៥២២)
-បទធ្វើឲ្យបាត់ជំនឿលើសេចក្តីសម្រេចរបស់តុលាការ (មាត្រា៥២៣)។

ផលប៉ះពាល់ដែលកាន់តែធ្ងន់ឡើងនៃបទបញ្ញត្តិទាំងនេះ ជាពិសេស ប្រសិនបើអនុវត្តវាខុស អាចជាការរិតត្បិតយ៉ាងធ្ងន់ធ្ងរដល់សេរីភាពនៃការបញ្ចេញមតិ។

បទបញ្ញត្តិទាំងអស់នេះ ចែងមកទំនងជាមានការជាន់គ្នាជាច្រើនពីមាត្រាមួយទៅមាត្រាមួយ ហើយដែលអាចនាំឲ្យជនដែលត្រូវចោទប្រកាន់ និងត្រូវផ្តន្ទាទោស ទទួលទោសពីបទល្មើសច្រើនក្នុងអង្គហេតុតែមួយ ជាហេតុនាំឲ្យមានទោសគុកកាន់តែវែងឡើង និងធ្វើឲ្យទោសពិន័យកើនឡើងខ្ពស់ដែរ។

ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស សូមលើកជាអនុសាសន៍ថា បើអាចធ្វើទៅបាន បទបញ្ញត្តិមួយចំនួនគួរត្រូវលុបចោល ឬដាក់បញ្ចូលគ្នា ដើម្បីធានាថា បុគ្គលទាំងឡាយ មិនអាចត្រូវផ្តន្ទាទោសពីបទល្មើសច្រើនករណីស្រដៀងគ្នា ក្នុងពេលតែមួយ។

ការប្រើពាក្យពេជន៍ក្នុងបទបញ្ញត្តិភាគច្រើនបើកចំហឲ្យមានការបកស្រាយទូលំទូលាយដែលអាចនាំឲ្យមានការបកស្រាយតាមទំនើងចិត្ត មិនស្របនឹងរដ្ឋធម្មនុញ្ញ និងបទដ្ឋានអន្តរជាតិទាំងឡាយស្តីពីសេរីភាពនៃការបញ្ចេញមតិ។

ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស សូមលើកជាអនុសាសន៍ថា ទស្សនៈទាំងឡាយដូចជា "អសុទ្ធចិត្ត" "ការដាក់សំពាធលើយុត្តាធិការ" ដែលបើកចំហឲ្យមានការបកស្រាយជាអត្តនោម័ត គួរតែកំណត់ន័យឲ្យបានច្បាស់លាស់។

## មាត្រា៣០៥: បទបរិហារកេរ្តិ៍ជាសាធារណៈ

រឿងរ៉ាវថ្មីៗនៃការប្រើប្រាស់បណ្តឹងបរិហាកេរ្តិ៍ នៅក្នុងប្រទេសកម្ពុជា ត្រូវបានមើលឃើញថាជាការប្រើប្រាស់ហួសហេតុនៃបទបញ្ញត្តិព្រហ្មទណ្ឌ ទៅលើបទបរិហារកេរ្តិ៍។ ទន្ទឹមនឹងបុគ្គលទាំងឡាយ ព្យាយាមការពារខ្លួនដោយធម្មានុរូប ពីការវាយប្រហារមិនស្របច្បាប់ លើកិត្តិយស និងកិត្តិស័ព្ទរបស់ខ្លួន ករណីទាំងនេះ គួរត្រូវបានដោះស្រាយជាធម្មតាតាមរយៈបណ្តឹងរដ្ឋប្បវេណី ដើម្បីទទួលសំណងខូចខាតដែលសមមាត្រទៅនឹងព្យសនកម្មដែលទទួលរង។ បទល្មើសព្រហ្មទណ្ឌបរិហារកេរ្តិ៍ ប្រសិនបើមានមែន គួរតែរក្សាទុក សំរាប់តែករណីណាដែលធ្ងន់ធ្ងរបំផុតប៉ុណ្ណោះ ដែលព្យសនកម្មកើតឡើងដល់ជនរងគ្រោះនោះ គឺជាការអន្តរាយយ៉ាងធ្ងន់ ដែលគំរាមកំហែងដល់សុវត្ថិភាព ឬសមត្ថភាពផ្ទាល់ខ្លួនរបស់ពួកគេ ក្នុងការដឹកនាំជីវភាពធម្មតា។ ដោយសារតែការសំរេចចិត្តរបស់ខ្លួន ចូលក្នុងជីវភាពសាធារណៈ អ្នកនយោបាយ មិនគួររំពឹងទៅលើបទល្មើសព្រហ្មទណ្ឌបរិហារកេរ្តិ៍ ដើម្បីដោះស្រាយការវាយប្រហារដែលជាផ្នែកនៃកិច្ចដំណើរការលទ្ធិប្រជាធិបតេយ្យជាធម្មតានោះឡើយ។

មាត្រា៣០៥ ពង្រីកន័យបទបរិហារកេរ្តិ៍គ្របដណ្តប់ដល់ "ស្ថាប័ននានា" ដែលមិនមានចែងក្នុងបទបញ្ញត្តិទាំងឡាយនៃច្បាប់ព្រហ្មទណ្ឌអន្តរកាលអ៊ុនតាក់ទៀត។ តាមវិសាលភាពមួយដែលបទបញ្ញត្តិទាំងនេះ អាចត្រូវបានធ្វើយុត្តិកម្ម បទបញ្ញត្តិនានានៃបទព្រហ្មទណ្ឌបរិហារកេរ្តិ៍ គួរតែមានគោលដៅការពារកិត្តិស័ព្ទផ្ទាល់ខ្លួនរបស់បុគ្គល អនុលោមតាមសិទ្ធិជីវិតឯកជន (មាត្រា១៧នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ)។ វាមិនត្រឹមត្រូវទេដែលមាត្រានេះ ផ្តល់ការការពារដល់ស្ថាប័ន ដោយសារតែស្ថាប័នទាំងនេះ មិនអាចមានសិទ្ធិមនុស្សទេ តាមលក្ខណៈធម្មជាតិជាស្ថាប័នសាធារណៈ គ្មានសិទ្ធិជីវិតឯកជនទេ។ នៅក្នុងសង្គមប្រជាធិបតេយ្យណាក៏ដោយ ស្ថាប័នរដ្ឋាភិបាល ត្រូវជាកម្មវត្ថុក្នុងកំរិតខ្ពស់នៃការការរិះគន់ និងការពិនិត្យពិច័យ។ ក្នុងករណីដែលមានការបំពារបំពានទៅលើផលប្រយោជន៍បុគ្គល បុគ្គលសាមីនោះ គួរតែត្រូវបានផ្តល់អត្តសញ្ញាណរបស់ខ្លួន។ នាឱកាសមួយចំនួន ក្នុងសម័យប្រជុំរបស់ខ្លួនគណៈកម្មាធិការសិទ្ធិមនុស្សសហប្រជាជាតិ (ស្ថាប័នដែលឃ្លាំមើលការអនុវត្តន៍ កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ) បានព្រមានឲ្យប្រុងប្រយ័ត្ន ចំពោះការធ្វើព្រហ្មទណ្ឌនីយកម្មនៃបទបរិហារកេរ្តិ៍ ហើយមានការឯកភាពគ្នាទូទៅជាអន្តរជាតិកាន់តែកើនឡើងថា បទល្មើសព្រហ្មទណ្ឌបរិហារកេរ្តិ៍ បង្ហាញពីការរំលោភបំពានលើសេរីភាពនៃការបញ្ចេញមតិ លើកលែងតែក្នុងករណីធ្ងន់ធ្ងរបំផុតមួយចំនួនដែលការបរិហារកេរ្តិ៍បណ្តាលឲ្យកើតមានព្យសនកម្មធ្ងន់ធ្ងរ។

មាត្រា៣០៥ ទំនងជាបង្ហាញថា រឿងពិតមិនចាំបាច់ឲ្យមានការការពារខ្លួនពីបទបរិហារកេរ្តិ៍ជាសាធារណៈទេ។ ប៉ុន្តែ អាចមានកាលៈទេសៈណាមួយ ដែលការពោលអះអាងមួយ ដោយផ្អែកទៅលើហេតុការណ៍ពិត ក៏អាចជាការបរិហារកេរ្តិ៍ដែរ ប្រសិនបើរឿងពិតនៃការពោលអះអាងនោះ អាចត្រូវបានលាតត្រដាង ហេតុនេះ គួរតែមានបទបញ្ញត្តិណាមួយ ផ្តល់ការការពារជាសក្តានុពលពីបទបរិហារកេរ្តិ៍បែបនេះដែរ។

ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស សូមលើកជាអនុសាសន៍ថា មាត្រា៣០៥ គួរត្រូវធ្វើវិសោធនកម្មដើម្បីៈ

- អនុវត្តចំពោះតែមនុស្សជាឯកត្តបុគ្គល ដោយមានគោលដៅច្បាស់លាស់នៃការការពារសិទ្ធិជីវិតឯកជនរបស់គេតែប៉ុណ្ណោះ។
- គួរតែរក្សាទុកសំរាប់តែករណីធ្ងន់ធ្ងរបំផុត ដែលជនរងគ្រោះបានទទួលរងព្យសនកម្ម ឬការគំរាមកំហែងធ្ងន់ធ្ងរដល់សុវត្ថិភាពផ្ទាល់ខ្លួនរបស់ពួកគេ។
- អនុញ្ញាតឲ្យរឿងពិតនៃការពោលអះអាង ថាជាការការពារមួយប្រកបដោយសក្តានុពលសំរាប់ជនត្រូវចោទ។

ជាទូទៅជាងនេះ ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សសូមលើកជាអនុសាសន៍ថា រឿងក្តីបរិហារកេរ្តិ៍គួរតែត្រូវបានដោះស្រាយដោយតុលាការរដ្ឋប្បវេណី អនុលោមតាមបទបញ្ញត្តិទាំងឡាយ ដែលមានរួចមកហើយ ចំពោះបណ្តឹងរដ្ឋប្បវេណីសំរាប់បទបរិហារកេរ្តិ៍។

បទល្មើសព្រហ្មទណ្ឌបរិហារកេរ្តិ៍ បើរក្សាទុក គួរតែត្រូវរក្សាទុកសំរាប់តែករណីពិសេស ដែលព្យសនកម្មបង្កឡើងដល់ជនរងគ្រោះ មានលក្ខណ:ធ្ងន់ធ្ងរហួសហេតុ ដូចជាការគំរាមកំហែងដល់សុវត្ថិភាពផ្ទាល់ខ្លួន ឬដល់អាយុជីវិតជាដើម។

គួរឲ្យកត់សំគាល់ថា ឯកសារជាភាសារខ្មែរនៃបទបញ្ញត្តិនេះមានឃ្លា " ក្នុងសាលប្រជុំសាធារណៈ " ទំនងជាមានន័យច្រើនលើសលប់ពេក ពីព្រោះសាលប្រជុំសាធារណៈ ជាកន្លែងសាធារណៈ។ សំណៅជាភាសាបារាំង មានន័យត្រឹមតែ " ការប្រជុំសាធារណៈ " ប៉ុណ្ណោះ។

## មាត្រា៣០៧: បទជេរប្រមាថជាសាធារណៈ

បទបញ្ញត្តិនេះ ឆ្លើយតបយ៉ាងទូលាយ ចំពោះបទបញ្ញត្តិស្ដីពីការជេរប្រមាថក្នុងបទបញ្ញត្តិព្រហ្មទណ្ឌអន្តរកាលអ៊ុនតាក់។ វាក្ដោបពាក្យប្រមាថ ពាក្យមើលងាយ ឬពាក្យទ្រគោះដែលគ្មានការទំលាក់កំហុសទៅលើអំពើណាមួយ។ បទបញ្ញត្តិនេះ អាចជាការរិតត្បិតយ៉ាងខ្លាំងទៅលើសេរីភាពដើម្បីសំដែងមតិ ប្រសិនបើមតិនេះ ត្រូវបានវិនិច្ឆ័យថាជាការជេរប្រមាថ ជាការមើលងាយ ឬជាការទ្រគោះ - តាមការវាយតម្លៃជាអត្តនោម័ត។

ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សព្រួយបារម្ភថា បទបញ្ញត្តិនេះ ត្រូវបានបកស្រាយ ដោយពឹងផ្អែកទៅលើធាតុអត្តនោម័តិ ដែលនឹងពិបាកអនុវត្តក្នុងទិដ្ឋភាពជាក់ស្ដែង ដោយជៀសមិនផុតពីការរិះគន់ថា វាទំនងជាត្រូវយកមកអនុវត្តតាមទំនើងចិត្ត និងជាការរិតត្បិតមិនត្រឹមត្រូវ ទៅលើសេរីភាពនៃការបញ្ចេញមតិ និងយោបល់។

ការិយាល័យខ្ពត្តមស្នងការសិទ្ធិមនុស្ស សូមលើកជាអនុសាសន៏ថា បទបញ្ញត្តិនេះ គួរតែត្រូវធ្វើវិសោធនកម្ម ដើម្បីធានាឲ្យការបញ្ចេញមតិត្រូវទទួលបានការការពារគ្រប់គ្រាន់ ហើយថា នេះជាតុល្យភាពត្រឹមត្រូវ រវាងការការពារកិត្តិស័ព្ទបុគ្គល សីលធម៌ និងសណ្ដាប់ធ្នាប់សាធារណ: និងការដាក់កំហិតមិនត្រឹមត្រូវដល់សេរីភាពនៃការបញ្ចេញមតិ។

## មាត្រា៣០៩: នីតិវិធីបណ្ដឹងចំពោះបទបរិហារកេរ្តិ៍ និងជេរប្រមាថ

នៅពេលដែលមនុស្សគ្រប់រូប រួមទាំងអ្នកនយោបាយ និងបុគ្គលផ្សេងៗក្នុងជីវភាពសាធារណៈផង មានសិទ្ធិក្នុងការការពារកិត្តិស័ព្ទរបស់ខ្លួន សារៈសំខាន់ជាមូលដ្ឋានសំរាប់លទ្ធិប្រជាធិបតេយ្យ ក្នុងការពិភាក្សាដេញដោលដោយសេរី គ្មានការរារាំង និងផុសផុល ពីបញ្ហាប្រយោជន៍សាធារណៈ[2] មានន័យថា មនុស្សបែបនេះ ត្រូវផ្ដល់ភាពអនុគ្រោះដល់ការពិភាក្សាដេញដោលឲ្យបានច្រើន ជាជាងទុកដាក់ថាជារឿងក្ដី ប្រសិនបើពួកគេជាបុគ្គលឯកជន។

ក្រមនេះ មិនបានធ្វើការបែងចែកឲ្យដាច់ រវាងបទបរិហារកេរ្តិ៍ទាក់ទងនឹងទង្វើរបស់មន្ត្រី ដែលបំពេញការងារក្នុងនាមជាបុគ្គលផ្ទាល់ខ្លួន និងមន្ត្រីដែលបំពេញការងារក្នុងនាមជាសាធារណៈ។ តាមពាក្យពេជន៍ក្នុងក្រម ស្ថាប័នមួយ (របស់រដ្ឋាភិបាល) អាចដាក់ពាក្យបណ្ដឹងប្រឆាំងនឹងបុគ្គលដែលបានបរិហារកេរ្តិ៍មន្ត្រីសាធារណៈមួយរូបចំពោះទង្វើសកម្មភាពដែលបានប្រព្រឹត្តក្នុងនាមជាបុគ្គលខ្លួនគាត់ផ្ទាល់។

ការិយាល័យខ្ពត្តមស្នងការសិទ្ធិមនុស្សសូមលើកជាអនុសាសន៏ថា គួរតែធ្វើការបែងចែកឲ្យបានច្បាស់លាស់រវាងមន្ត្រីដែលទទួលរងការបរិហារកេរ្តិ៍ក្នុងនាមជាមន្ត្រីសាធារណ: និងក្នុងនាមជាបុគ្គលឯកជនមួយរូប។ ប្រសិនបើបទបរិហារកេរ្តិ៍គាត់ ទាក់ទងនឹងទង្វើក្នុងជីវិតឯកជនរបស់គាត់ ស្ថាប័នរបស់មន្ត្រីសាធារណ:នោះ មិនគួរពាក់ព័ន្ធក្នុងការដាក់ពាក្យបណ្ដឹងសំរាប់ផលប្រយោជន៏មន្ត្រីនោះឡើយ។

ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស សូមស្វាគមន៍ចំពោះបទបញ្ញត្តិក្នុងមាត្រា៣០៩ ដែលអនុញ្ញាតឲ្យព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ដោយស្វ័យប្រវត្តិ " ប្រសិនបើការបរិហារកេរ្តិ៍ ឬជេរប្រមាថនោះ ត្រូវបានធ្វើឡើងប្រឆាំងនឹងបុគ្គលម្នាក់ ឬក្រុមនៃបុគ្គល ដោយមូលហេតុដើមកំណើត ជាតិពន្ធុ ពូជសាសន៍ សញ្ជាតិ ឬជំនឿសាសនារបស់បុគ្គលនោះ " ដែលស្របទៅនឹងកាតព្វកិច្ចរបស់ប្រទេសកម្ពុជា ក្រោមសន្ធិសញ្ញាសិទ្ធិមនុស្សទាំងអស់ ជាពិសេសអនុសញ្ញាអន្តរជាតិស្ដីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍។ ទោះបីយ៉ាងណាក៏ដោយ ការិយាល័យខ្ពត្តមស្នងការសិទ្ធិមនុស្ស សូមលើកជាអនុសាសន៏ថា បទបញ្ញត្តិនេះគួរតែកំណត់លក្ខណ:សម្បត្តិឲ្យបានគ្រប់គ្រាន់ ដើម្បីកំណត់ព្រំដែនឲ្យកាន់តែច្បាស់លាស់ជាងនេះ និងជៀសវាងការរិតត្បិតហួសហេតុពេក ឧទាហរណ៍: ដោយបន្ថែមបែបបទខ្លះនៃលក្ខណ:សម្បត្តិដូចជា " ប្រសិនបើការបរិហារកេរ្តិ៍ អាចបង្កើតជាការគំរាមកំហែងពិតប្រាកដ និងជាក់ស្ដែង ដល់សណ្ដាប់ធ្នាប់សាធារណ: " ជាដើម។

---

[2]សូមមើលរឿងក្ដី Aduayom និងអ្នកដទៃទៀត ទល់នឹងរដ្ឋ Togo, បណ្ដឹងលេខ៤២២-៤២៤/១៩៩០

# បទបញ្ញត្តិទាំងឡាយដែលរិតត្បិតសេរីភាពនៃការបញ្ចេញមតិ
# ក្នុងផលប្រយោជន៍ច្បាប់ និងសណ្តាប់ធ្នាប់

ក្រមនេះ រាប់បញ្ចូលបទបញ្ញត្តិនានា ដែលមានគោលដៅទប់ស្កាត់បុគ្គលទាំងឡាយ មិនឲ្យប្រើប្រាស់សេរីភាពនៃការបញ្ចេញមតិតាមមធ្យោបាយនានា ដែលនឹងនាំឲ្យអន្តរាយដល់ច្បាប់ និងសណ្តាប់ធ្នាប់ ព្រមទាំងសុចរិតភាពនៃដំណើរការតាមនីតិវិធីច្បាប់។

## មាត្រា៣១១: បទប្តឹងបរិហារបង្កាច់កេរ្តិ៍

បទល្មើសនេះ មិនដែលមានទេពីមុនមក ក្រោមបទបញ្ញត្តិព្រហ្មទណ្ឌអន្តរកាលអ៊ុនតាក់។ សនិទានភាពនៃបទបញ្ញត្តិនេះ គឺបញ្ចៀសមិនឲ្យខ្ជះខ្ជាយធនធានសាធារណៈដែលមានកំណត់ ទៅលើបណ្តឹងដែលមិនសមហេតុផល។ ថ្វីបើប្រការនេះ មានលក្ខណៈសំខាន់ក៏ដោយ ជាពិសេសក្នុងបរិបទកម្ពុជា ជាទីដែលធនធានតុលាការមានកំណត់ បទបញ្ញត្តិនេះ អាចមានអានុភាពរិតត្បិតមួយទៅលើការថ្កោលទោសស្របច្បាប់ចំពោះអំពើល្មើស កាលបើមានភាពមិនប្រាកដប្រជា ឬមានភាពមន្ទិលសង្ស័យ ដោយសារតែថា តើអំពើល្មើសមួយត្រូវបានគេប្រព្រឹត្តមែន ឬមិនមែន។ វាសំខាន់ណាស់ដែលប្រព័ន្ធតុលាការ ត្រូវលើកទឹកចិត្តដល់ "អ្នកដែលហ៊ានថ្កោលទោសស្របច្បាប់ចំពោះអំពើពុករលួយ" ហើយមិនត្រូវដាក់កំហិតមិនត្រឹមត្រូវទៅលើសេរីភាពនៃការបញ្ចេញមតិ ដើម្បីរារាំងប្រជាពលរដ្ឋមិនឲ្យសាកសួរនូវអំពើទាំងឡាយ ដែលអាចជាអំពើខុសច្បាប់ បើទុកជាអំពើទាំងនោះ មិនត្រូវបានគេស៊ើបអង្កេតសមរម្យ ឬមិនត្រូវបានគេផ្ទៀងផ្ទាត់ក៏ដោយ។ អានុភាពនៃបទបញ្ញត្តិនេះ កាលបើអនុវត្តមិនត្រឹមត្រូវ វាមុខជាធ្វើឲ្យអន្តរាយ ដល់កិច្ចខំប្រឹងប្រែងរបស់រដ្ឋាភិបាល ក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ។ នៅក្នុងប្រទេសមួយ ដែលតុលាការមានភាពទន់ខ្សោយ ហើយតែងតែប្រព្រឹត្តអំពើពុករលួយ សក្តានុពលនៃការអនុវត្តន៍មិនបានត្រឹមត្រូវនូវបទបញ្ញត្តិនេះ កាន់តែកើនឡើង ដោយសារតែចៅក្រមពុករលួយ អាចលើកបណ្តឹងចោល ទោះជាបណ្តឹងនោះធ្វើត្រឹមត្រូវតាមច្បាប់ក៏ដោយ ហើយក្រោយមក ក៏ធ្វើការចោទប្រកាន់ដើមបណ្តឹងនោះវិញ តាមមាត្រា៣១១នៃក្រមនេះ។

ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស សូមលើកជាអនុសាសន៍ថា បទបញ្ញត្តិនេះ គួរតែត្រូវធ្វើវិសោធនកម្ម ដើម្បីផ្តល់ការការពារដល់ " អ្នកដែលហ៊ានថ្កោលទោសស្របច្បាប់ចំពោះអំពើពុករលួយ " និងធានាថា បទបញ្ញត្តិនេះ អាចអនុវត្តបាន តែក្នុងករណីនៃការរិះគន់ដែលមានចេតនាទុច្ចរិតតែប៉ុណ្ណោះ។

## មាត្រា៤២៥: បទក្លែងព័ត៌មាន

នៅខណៈដែលបទបញ្ញត្តិនេះត្រូវបានដាក់កំហិតដល់ការការពារទ្រព្យសម្បត្តិ វាមានការពាក់ព័ន្ធនឹងបទបញ្ញត្តិស្តីពីការផ្សាយព័ត៌មានមិនពិត ក្នុងបទបញ្ញត្តិព្រហ្មទណ្ឌអន្តរកាលអ៊ុនតាក់ដែលតែងតែយកមកអនុវត្តមិនបានត្រឹមត្រូវ។ បទបញ្ញត្តិនេះ នឹងទទួលបានប្រយោជន៍ពីលក្ខណៈសម្បត្តិខ្លះៗ ដើម្បីបំភ្លឺ គឺជាការអនុវត្តន៍យ៉ាងត្រឹមត្រូវ។

## មាត្រា៤២៦: ទោសបន្ថែម: ប្រភេទ និងរយៈពេល

ទោសបន្ថែម អនុវត្តចំពោះមាត្រា៤២៥ ទំនងជាធ្ងន់ហួសហេតុ។ ឧទាហរណ៍: ការដកជាស្ថាពរនៃសិទ្ធិខ្លះជាពលរដ្ឋ ទំនងជាធ្ងន់ធ្ងរពេក។ មិនដូចបទបញ្ញត្តិស្តីពីបទបរិហារកេរ្តិ៍ទេ នៅត្រង់ចំណុចនេះ ពុំមានការនិយាយយោងជាក់លាក់ទៅរកអង្គការសារព័ត៌មាន ដែលត្រូវគ្រប់គ្រងដោយច្បាប់សារព័ត៌មាននោះឡើយ ដែលអាចមានន័យថា ប្រសិនបើនិពន្ធនាយក ឬអ្នកសារព័ត៌មានណាម្នាក់ ត្រូវផ្តន្ទាទោសពីបទក្លែងព័ត៌មាន រដ្ឋអាចរឹបអូសយកសម្ភារៈបោះពុម្ពផ្សាយ ហើយបិទកាសែតនោះមិនឲ្យផ្សព្វផ្សាយជាស្ថាពរតែម្តង។ ប្រការនេះ មានសក្តានុពលធ្វើឲ្យអន្តរាយជាខ្លាំងដល់សេរីភាពនៃការបញ្ចេញមតិ។

## មាត្រា៤៩៥: បទញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ

ជាគោលការណ៍ ការហាមប្រាមបទញុះញង់ឲ្យប្រព្រឹត្ត ឬប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋណាមួយ មានគោលដៅជាធម្មានុរូបនៃការការពារសិទ្ធិនានារបស់អ្នកដទៃឬសណ្តាប់ធ្នាប់សាធារណៈ អនុលោមតាមកាតព្វកិច្ចរបស់ប្រទេសកម្ពុជាក្រោមមាត្រា១៩(៣)នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ ទោះបីយ៉ាងណាក៏ដោយ ការចោទប្រកាន់ណាមួយក្នុងករណីដោយឡែកមួយ តាមពិតធ្វើឡើងត្រូវតែសំរាប់គោលបំណងនេះប៉ុណ្ណោះ ហើយមិនត្រូវព្យាយាម

បំបិទសម្លេងរិះគន់ឡើយ។ ការអនុវត្តន៍កន្លងមកនៅក្នុងប្រទេសកម្ពុជា បានបង្ហាញឲ្យឃើញពីនិន្នាការរបស់តុលាការមួយចំនួន ប្រើមិនត្រឹមត្រូវនូវបទបញ្ញត្តិស្តីពីបទញុះញង់ ដើម្បីរឹតត្បិតសកម្មភាពតស៊ូមតិតាមផ្លូវច្បាប់មួយចំនួន។

តាមពិត ក្នុងករណីបទញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋមិនបានសំរេច ត្រូវចែងឲ្យបានច្បាស់ថា មានការមើលឃើញប្រាកដប្រជាមួយថា នឹងមានការប្រព្រឹត្តបទឧក្រិដ្ឋ ឬថានឹងមានការគំរាមកំហែងដល់សណ្តាប់ធ្នាប់សាធារណៈ។ បុគ្គលខ្លះមានឥទ្ធិពលច្រើនជាងបុគ្គលផ្សេងៗទៀតនៅក្នុងសហគមមួយ ហើយប្រសិនបើបទញុះញង់ ដែលត្រូវចោទប្រកាន់នោះ គ្មានអ្វីសោះក្រៅតែពីពុតត្បុតធ្វើឫកជាក្លាហាន ឬភាពកំផ្លុកកំប្លែងដែលខ្វះសុភវិនិច្ឆ័យ ច្បាប់មិនគួរយកមកអនុវត្តឡើយ។ ស្រដៀងគ្នានេះដែរ បុគ្គលមិនគួរដាក់ឲ្យទទួលខុសត្រូវជំនួសអ្នកដទៃ ដោយសារតែការបកស្រាយខុសនូវការពោលអះអាងទាំងឡាយ ដែលធ្វើឡើងដោយសុទ្ធចិត្ត ដោយគ្មានចេតនាញុះញង់នោះឡើយ។

ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស ព្រួយបារម្ភថា ការចោទប្រកាន់ពីបទញុះញង់ មិនគួរត្រូវធ្វើក្នុងគោលបំណងបំបិទសម្លេងរិះគន់ រាប់ទាំងសម្លេងដែលលើកឡើងអំពីបញ្ហានយោបាយដែលរសើប ឬចម្រូងចម្រាសផងៗ ការចោទប្រកាន់ពីបទញុះញង់ គួរតែត្រូវធ្វើឡើង កាលបើគេអាចបង្ហាញឲ្យឃើញពីចំណងច្បាស់លាស់និងផ្ទាល់ ទៅនឹងបទល្មើសជាក់លាក់ណាមួយ ឬទៅនឹងហានិភ័យជាក់ស្តែងនិងពិតប្រាកដដែលនឹងបង្កឲ្យខូចខាតដល់សណ្តាប់ធ្នាប់សាធារណៈ។ ចំណងច្បាស់លាស់ដែលចាំបាច់ រវាងបទញុះញង់ និងបទល្មើសព្រហ្មទណ្ឌ ដែលអះអាងថាជាការញុះញង់ គួរត្រូវបញ្ជាក់ឲ្យបានច្បាស់ក្នុងក្រមនេះ ដើម្បីជៀសវាងការបកស្រាយតាមទំនើងចិត្ត និងការប្រើមិនត្រឹមត្រូវនៃបទបញ្ញត្តិនេះ។

## ករណីទាក់ទងនឹងអង្គការសារព័ត៌មាន

យោងតាមមាត្រា៣០៦ មាត្រា៣០៨ និងមាត្រា៤៩៧ ករណីបទបរិហារកេរ្តិ៍ បទជេរប្រមាថ និងបទញុះញង់ ទាក់ទងនឹងសារព័ត៌មាន (រាប់ទាំងអង្គការព័ត៌មានដែលចាក់ផ្សាយព័ត៌មាន) ត្រូវរក្សាទុកជាពិសេស ដើម្បីដោះស្រាយតាមឧបញ្ញត្តិនៃច្បាប់ស្តីពីរបបសារព័ត៌មានឆ្នាំ១៩៩៥។ ច្បាប់ស្តីពីរបបសារព័ត៌មាននេះ ការពារសិទ្ធិរបស់អ្នកសារព័ត៌មានយ៉ាងជាក់ច្បាស់ ដើម្បីឲ្យពួកគេសម្តែងមតិដោយសេរី (មាត្រា២០) ហើយផ្តល់ដំណោះស្រាយសមស្រប ដូចជាការកែតម្រូវ បើទោះជាទោសពិន័យអប្បបរមា មានកំរិតខ្ពស់ជាងទោសពិន័យអប្បបរមា ក្រោមក្រមព្រហ្មទណ្ឌនេះ សំរាប់បទបរិហារកេរ្តិ៍ក៏ដោយ។

គួរកត់សំគាល់ថា មាត្រា៥២២ និងមាត្រា៥២៣ ដែលទាក់ទងនឹងចំណាត់ការរបស់តុលាការ មិនដាក់បញ្ចូលបទបញ្ញត្តិស្របគ្នានានាសំរាប់អង្គការសារព័ត៌មានឡើយ។ ប្រការនេះសំខាន់ណាស់ ដោយសារតែមាត្រា៤ នៃច្បាប់ស្តីពីរបបសារព័ត៌មាន និយាយយោងជាពិសេសដល់ការរាយការណ៍ពីចំណាត់ការតាមនីតិវិធីរបស់តុលាការ។

ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស សូមលើកជាអនុសាសន៍ថា បទបញ្ញត្តិនានា កំពុងអនុវត្តច្បាប់ស្តីពីរបបសារព័ត៌មានចំពោះអង្គការសារព័ត៌មាន ដែលរាយការណ៍អំពីចំណាត់ការរបស់តុលាការ គួរតែត្រូវដាក់បញ្ចូលពីខាងក្រោយមាត្រា៥២២ និងមាត្រា៥២៣។ ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស សូមលើកជាអនុសាសន៍ផងដែរថា គួរចាត់ឲ្យមានដំណោះស្រាយស្រដៀងគ្នានេះ សំរាប់ករណីដទៃៗទាំងអស់នៃបទបរិហារកេរ្តិ៍ និងបទជេរប្រមាថ ដោយប្រើប្រាស់បទបញ្ញត្តិទាំងឡាយដែលមានស្រាប់ក្នុងក្រមរដ្ឋប្បវេណី។

## ការរឹតត្បិតលើសេរីភាពនៃការបញ្ចេញមតិ ដែលមានគោលដៅការពារសុចរិតភាព និងឯករាជ្យភាពរបស់តុលាការ

**មាត្រា៥២២** ហាមឃាត់នូវការផ្សព្វផ្សាយនៃការអត្ថាធិប្បាយណាមួយដើម្បីដាក់សម្ពាធទៅលើយុត្តាធិការជាគោលការណ៍ បទបញ្ញត្តិនេះ មានគោលដៅរក្សាឯករាជ្យភាពតុលាការ គឺជាផ្នែកមួយយ៉ាងសំខាន់របស់សង្គមប្រជាធិបតេយ្យ ដែលត្រូវបានធានាការពារដោយរដ្ឋធម្មនុញ្ញ និងសន្ធិសញ្ញាអន្តរជាតិ។ បទបញ្ញត្តិនេះ ស្របគ្នានឹងវិធានដែលហាមមិនឲ្យផ្សព្វផ្សាយ តាមប្រព័ន្ធសារព័ត៌មាន នូវរឿងក្តីដែលតុលាការកំពុងពិភាក្សា មិនទាន់សំរេចជាស្ថាពរ (sub judice rule) ដែលអនុវត្តនៅក្នុងយុត្តាធិការ Common Law ជាច្រើន។

ពាក្យ " ដាក់សម្ពាធលើតុលាការ " បើកចំហឲ្យមានការបកស្រាយយ៉ាងទូលំទូលាយ។ ឧទាហរណ៍: តើពាក្យនេះ នឹងរាប់បញ្ចូលទាំងសេចក្តីថ្លែងការណ៍របស់អង្គការក្រៅរដ្ឋាភិបាល ដែលទាមទារឲ្យតុលាការសំរេចសេចក្តី ស្រប

តាមការទាមទាររបស់ជនរងគ្រោះ ឬជនជាប់ចោទដែរឬទេ? ហើយចុះសារណាប្រឹក្សាយោបល់លើផ្លូវច្បាប់ដែលដាក់ជូនទៅតុលាការ យ៉ាងម៉េចដែរ? ឬក៏សន្និសីទកាសែតមួយ ធ្វើឡើងដោយជនជាប់ចោទ មុនពេលប្រកាសសាលក្រមយ៉ាងម៉េចដែរ? ឬក៏ការអន្តរាគមន៍ដោយរដ្ឋមន្ត្រីជាន់ខ្ពស់ម្នាក់ដែលសំដែងនូវទស្សនៈមួយ ថាតើតុលាការ គួរតែចាត់ការចំពោះករណីដោយឡែកណាមួយដែរឬទេនោះ ជាដើម?

នៅក្នុងប្រទេសមួយ ដែលប្រព័ន្ធតុលាការត្រូវបានទទួលស្គាល់ថានៅមានភាពទន់ខ្សោយ បទបញ្ញត្តិនេះ អាចបង្ហាញថាមានបញ្ហា បើទុកជាវា មិនប៉ះពាល់ដល់អាទិភាពកំណែទម្រង់ច្បាប់ និងតុលាការ របស់រដ្ឋាភិបាលក៏ដោយ។ បទបញ្ញត្តិនេះ អាចត្រូវយកមកប្រើដើម្បីដាក់កំហិតទៅលើការរិះគន់ស្របច្បាប់ និងសេរីភាពនៃការបញ្ចេញមតិ។ ពាក្យថា "ការអត្ថាធិប្បាយ" នៅក្នុងបទបញ្ញត្តិនេះ មានលក្ខណៈស្រពេចស្រពិល។ បទបញ្ញត្តិនេះ គួរតែកំណត់ន័យឲ្យបានច្បាស់លាស់ពីប្រភេទនៃអំពើដែលនឹងបង្កើតជា " ការជ្រៀតជ្រែក " ដោយទទួលស្គាល់ថា ប្រជាពលរដ្ឋខ្លះ មានឥទ្ធិពលច្រើនជាងអ្នកដទៃទៀតនៅក្នុងសង្គមកម្ពុជាៈ ការអត្ថាធិប្បាយរបស់រដ្ឋមន្ត្រីរដ្ឋាភិបាលម្នាក់ អាចដាក់សម្ពាធច្រើនជាងការអត្ថាធិប្បាយពីបុគ្គលឯកជនអនាមិកម្នាក់។

ដូចបទបរិហារកេរ្តិ៍ និងបទញុះញង់ដែរ គួរតែមានបទបញ្ញត្តិមួយចែងថា អង្គការសារព័ត៌មាន ត្រូវគ្រប់គ្រងជាក់លាក់ដោយច្បាប់ស្តីពីរបបសារព័ត៌មាន ។

ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស សូមលើកជាអនុសាសន៍ថា បទបញ្ញត្តិនេះ គួរតែកំណត់ន័យឲ្យបានច្បាស់លាស់ជាងនេះពីអ្វីដែលបង្កើតជាសម្ពាធមិនត្រឹមត្រូវ ដោយពិចារណាអំពីលទ្ធភាពរបស់ជនត្រូវចោទ មានឥទ្ធិពលទៅលើដំណើរការតុលាការ។ ភាគីដែលមិនសុខចិត្ត ឬភាគីដែលមានប្រយោជន៍ដទៃទៀត ជានិច្ចកាលគួរតែត្រូវបានអនុញ្ញាតឲ្យសម្តែងមតិរបស់ខ្លួនដោយសេរី ជាសាធារណៈអំពីករណីមួយ ប៉ុន្តែអ្នកនយោបាយ និងប្រជាពលរដ្ឋដែលមានឥទ្ធិពលដទៃទៀត មិនគួរត្រូវបានអនុញ្ញាតឲ្យដាក់សម្ពាធ ទៅលើតុលាការនោះឡើយ។ អង្គការសារព័ត៌មាន គួរតែត្រូវបានគ្រប់គ្រងដោយច្បាប់ស្តីពីរបបសារព័ត៌មាន។

ដូចគ្នានេះដែរ មាត្រា៥២៣ ដាក់ឲ្យនៅក្រៅច្បាប់នូវបទប៉ុនប៉ងធ្វើឲ្យបាត់ជំនឿលើសេចក្តីសម្រេចរបស់តុលា-ការ។ នៅក្នុងប្រទេសមួយដែលសូម្បីតែរដ្ឋាភិបាលរបស់ខ្លួនក៏បានទទួលស្គាល់ថា មានប្រព័ន្ធតុលាការមួយទន់ខ្សោយនៅឡើយនោះ បទបញ្ញត្តិនេះទំនងជាមិនសមហេតុផលទេ ហើយមានការរិតត្បិតមិនសមាមាត្រទៅលើសេរីភាពនៃការបញ្ចេញមតិ។ ភាគីនានាក្នុងរឿងក្តី ជានិច្ចកាលគួរតែត្រូវបានអនុញ្ញាតឲ្យបញ្ចេញទស្សនៈរបស់ពួកគេ អំពីលទ្ធផលនៃសេចក្តីសម្រេចរបស់តុលាការ។ នេះគឺជាផ្នែកមួយនៃការយល់ដឹងជាមូលដ្ឋានបំផុតចំពោះសេរីភាពនៃការបញ្ចេញមតិ។ ការសម្តែងមតិអំពីលទ្ធផលនៃសេចក្តីសម្រេចរបស់តុលាការ មិនគួរចាត់ទុកថាជាការជ្រៀតជ្រែកទេ ដោយសារតែសេចក្តីសម្រេចនោះ ត្រូវបានធ្វើរួចទៅហើយ។ ផ្អែកលើបទអន្តរាគមន៍ថ្មីៗ ដែលបានរាយការណ៍ក្នុងសារព័ត៌មានសមាជិកជាន់ខ្ពស់រាជរដ្ឋាភិបាលមួយចំនួន អាចត្រូវទទួលខុសត្រូវខាងព្រហ្មទណ្ឌ ចំពោះការអត្ថាធិប្បាយនានា ស្តីពីប្រសិទ្ធភាពរបស់តុលាការ ក្រោមបទបញ្ញត្តិនេះ។

ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស សូមលើកជាអនុសាសន៍ថា បទបញ្ញត្តិនេះ គួរតែត្រូវដកចេញពីក្រមនេះ ពីព្រោះ វាជាការដាក់កំហិតមិនចាំបាច់ និងមិនមានប្រយោជន៍ដល់សេរីភាពនៃការបញ្ចេញមតិ ហើយក៏ជាការបើកចំហឲ្យមានការរិះគន់ក្នុងន័យស្ថាបនាទៅលើប្រព័ន្ធតុលាការមួយ ដែលមានភាពទន់ខ្សោយ។ បើរក្សាទុកបទបញ្ញត្តិនេះ គួរតែត្រូវកំណត់លក្ខណៈសម្បត្តិឲ្យបានច្បាស់លាស់ដោយការផាត់ចេញជាក់លាក់ចំពោះអង្គការសារព័ត៌មាន និងអ្នកអត្ថាធិប្បាយដទៃទៀត។

រៀបរៀងដោយៈ

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស

ការិយាល័យប្រចាំនៅកម្ពុជា

ភ្នំពេញ ថ្ងៃទី៦ ខែតុលា ឆ្នាំ២០០៩

---

## សម្រង់ឯកសារយោងនៃសន្ធិសញ្ញាអន្តរជាតិ និងប្រភពដទៃទៀតដែលពាក់ព័ន្ធ

កំណត់ចំណាំ: គឺជាសន្ធិសញ្ញាអន្តរជាតិទាំងអស់ ដែលត្រូវបានផ្ដល់សច្ចាប័នដោយប្រទេសកម្ពុជា ហើយត្រូវបានធានាការពារតាមមាត្រា៣១នៃរដ្ឋធម្មនុញ្ញ។

### ១- អនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប

មាត្រា ១:

១. ដើម្បីគោលបំណងនៃអនុសញ្ញានេះ ពាក្យ " ទារុណកម្ម " មានន័យថា អំពើទាំងឡាយណាដែលនាំឱ្យមានការឈឺចាប់ ឬរងទុក្ខយ៉ាងខ្លាំង ទោះផ្លូវកាយ ឬផ្លូវចិត្តក្ដីដែលត្រូវបានបង្កឡើងដោយចេតនាទៅលើជនណាម្នាក់ ក្នុងគោលបំណងទាំងឡាយ ដូចជា ទាញយកព័ត៌មាន ឬចម្លើយសារភាពពីជននោះ ឬតតិយជនណាម្នាក់ ដាក់ទណ្ឌកម្មជននោះ ចំពោះអំពើណាមួយដែលជននោះ ឬតតិយជនណាម្នាក់ បានប្រព្រឹត្ត ឬសង្ស័យថាបានប្រព្រឹត្ត ឬបំភិតបំភ័យ ឬបង្ខិតបង្ខំជននោះ ឬតតិយជនណាម្នាក់ ឬដើម្បីមូលហេតុណាផ្សេងទៀតដែលផ្អែកលើការរើសអើងណាមួយ កាលបើការឈឺចាប់ ឬការរងទុក្ខ បង្កដោយមន្ត្រីសាធារណៈ ឬជនផ្សេងទៀត តាមការញុះញង់ ឬការព្រមព្រៀង ឬផ្ដើមគំនិតរបស់មន្ត្រីសាធារណៈ ឬជនផ្សេងទៀតដែលបំពេញតួនាទីជាផ្លូវការ។ ពាក្យទារុណកម្ម មិនរាប់បញ្ចូលនូវការឈឺចាប់ ឬការរងទុក្ខ ដែលកើតជាប់ ឬម្ដងម្កាល ពីទណ្ឌកម្មត្រឹមត្រូវតាមច្បាប់ឡើយ។

២. មាត្រានេះមិនប៉ះពាល់ដល់លិខិតុបករណ៍អន្តរជាតិ ឬច្បាប់ជាតិទាំងឡាយដែលមាន ឬអាចមានបទបញ្ញត្តិទូលំទូលាយជាងនេះឡើយ។

### ២- អនុសញ្ញាស្ដីពីសិទ្ធិកុមារ

មាត្រា ៣៧: រដ្ឋភាគីត្រូវធានាថា :

(ក) គ្មានកុមារណាម្នាក់ ត្រូវទទួលរងទារុណកម្ម ឬការប្រព្រឹត្តទៅលើខ្លួន ឬការផ្ដន្ទាទោសឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាបឡើយ[...]។ ទោសប្រហារជីវិត ឬដាក់គុកអស់មួយជីវិត ដោយគ្មានលទ្ធភាពដោះលែង មិនត្រូវដាក់ចំពោះបទល្មើសដែលប្រព្រឹត្តដោយមនុស្សមានអាយុក្រោម១៨ឆ្នាំឡើយ។

### ៣- អង្គការសហប្រជាជាតិ-គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្ម

សេចក្ដីសន្និដ្ឋាន និងអនុសាសន៍ចំពោះរបាយការណ៍ដំបូងរបស់ប្រទេសកម្ពុជាក្រោមអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០០៤ [...]។

៧-គណៈកម្មាធិការផ្ដល់អនុសាសន៍ថា រដ្ឋភាគី [កម្ពុជា]:

*(ក) ដាក់បញ្ចូលទៅក្នុងច្បាប់ជាតិរបស់ខ្លួននូវនិយមន័យនៃទារុណកម្ម ដូចមានចែងក្នុងមាត្រា១ នៃអនុសញ្ញា ហើយកំណត់ចរិកលក្ខណៈអំពើនានានៃទារុណកម្ម ថាជាបទល្មើសជាក់លាក់ ដែលត្រូវផ្ដន្ទាទោសឲ្យបានសមរម្យបំផុត [...]។*

### ៤- ពិធីសារបន្ថែមនៃអនុសញ្ញាស្ដីពីសិទ្ធិកុមារពាក់ព័ន្ធនឹងការលក់ដូរកុមារ ពេស្យាកម្មកុមារ និងរូបភាព ឬសម្ភារៈអាសអាភាសកុមារ

មាត្រា ៣

១. រដ្ឋភាគីនីមួយៗ ត្រូវធានាជាអប្បបរមាថា អំពើ និងសកម្មភាពខាងក្រោមនេះ ត្រូវទទួលការផ្ដន្ទាទោសយ៉ាងពេញលេញ ក្រោមច្បាប់ព្រហ្មទណ្ឌរបស់ខ្លួន ទោះជាបទល្មើសទាំងនោះ ត្រូវបានប្រព្រឹត្តនៅក្នុងប្រទេស ឬឆ្លងប្រទេស ឬជាលក្ខណៈបុគ្គល ឬជាលក្ខណៈចាត់តាំងក៏ដោយ :

(ក) ក្នុងបរិបទស្ដីពីការលក់កុមារ ដូចបានកំណត់ក្នុងមាត្រា២ :

(i) រាល់ការប្រគល់ ការបញ្ជូន ឬការទទួលយកកុមារ ទោះតាមមធ្យោបាយណាក៏ដោយ ក្នុងបំណង :

ក. ធ្វើអាជីវកម្មខាងផ្លូវភេទលើកុមារ

ខ. ផ្ទេរសរីរាង្គកុមារដើម្បីយកកម្រៃ

គ. ដាក់កុមារឱ្យធ្វើការងារដោយបង្ខំ

(ii) ការអូសទាញឱ្យយល់ព្រមលើសុំកូនដោយមិនត្រឹមត្រូវ ក្នុងនាមជាអន្តរការី ដោយរំលោភលើលិខិតុបករណ៍គតិយុត្តិអន្តរជាតិស្តីពីការសុំកូន ដែលកំពុងអនុវត្ត។

(ខ) ការឱ្យ ការទទួល ការធ្វើសញ្ជារកម្ម ឬការផ្គត់ផ្គង់កុមារសម្រាប់ពេស្យាកម្មកុមារ ដូចបានកំណត់ក្នុងមាត្រា២ ។

(គ) ការផលិត ការចែកចាយ ការផ្សព្វផ្សាយ ការនាំចូល ការនាំចេញ ការឱ្យ ការលក់ដូរ ឬការកាន់កាប់ សម្រាប់គោលបំណងខាងលើនូវរូបភាពឬសម្ភារៈអាសអាភាសកុមារ ដូចបានកំណត់ក្នុងមាត្រា២។

២. ដោយស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ជាតិរបស់រដ្ឋភាគី បទប្បញ្ញត្តិដូចគ្នានេះ ត្រូវអនុវត្តចំពោះការប៉ុនប៉ងប្រព្រឹត្តអំពើណាមួយដូចបានរៀបរាប់ខាងលើ ព្រមទាំងចំពោះការសមគំនិត ឬការចូលរួមប្រព្រឹត្តអំពើណាមួយដូចបានរៀបរាប់ខាងលើ។

៣. រដ្ឋភាគីនីមួយៗ ត្រូវដាក់បទល្មើសទាំងនេះ ជាបទល្មើសអាចផ្តន្ទាទោសបាន សមស្របទៅនឹងចរិតធ្ងន់ធ្ងរ នៃបទល្មើស។

៤. ដោយស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ជាតិរបស់ខ្លួន រដ្ឋភាគីនីមួយៗ ត្រូវចាត់វិធានការតាមការចាំបាច់ ដើម្បីកំណត់កាតព្វកិច្ចទទួលខុសត្រូវរបស់នីតិបុគ្គល ចំពោះបទល្មើសដូចមានកំណត់ក្នុងកថាខណ្ឌ១ នៃមាត្រានេះ។ ដោយស្ថិតក្រោមគោលការណ៍គតិយុត្តិនៃរដ្ឋភាគី កាតព្វកិច្ចទទួលខុសត្រូវរបស់នីតិបុគ្គល អាចមានខាងព្រហ្មទណ្ឌ រដ្ឋប្បវេណី ឬខាងរដ្ឋបាល [...]។

## ៥- កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

មាត្រា១៧

១. គ្មានជនណាម្នាក់ ត្រូវទទួលរងការជ្រៀតជ្រែក តាមអំពើចិត្ត ឬដោយខុសច្បាប់ ក្នុងជីវិតឯកជន គ្រួសារ លំនៅដ្ឋាន សំបុត្រឆ្លើយឆ្លងរបស់ខ្លួន ឬត្រូវទទួលរងការប៉ះពាល់ ដោយខុសច្បាប់ទៅលើកិត្តិយស និងកេរ្តិ៍ឈ្មោះរបស់ខ្លួនឡើយ។

១. ជនគ្រប់រូប មានសិទ្ធិទទួលបាននូវការការពារពីច្បាប់ ប្រឆាំងនឹងការជ្រៀតជ្រែក ឬការប៉ះពាល់ទាំងអស់នេះ។

មាត្រា១៩

២. ជនគ្រប់រូប មានសិទ្ធិប្រកាន់យកមតិយោបល់ដោយគ្មានការជ្រៀតជ្រែក។

៣. ជនគ្រប់រូប មានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ។ សិទ្ធិនេះ ត្រូវរាប់បញ្ចូលទាំងសេរីភាពក្នុងការស្រាវជ្រាវ ទទួល និងផ្សព្វផ្សាយព័ត៌មាន និងគំនិតសព្វបែបយ៉ាងដោយមិនគិតពីព្រំដែន ដោយផ្ទាល់មាត់ ជាលាយលក្ខណ៍អក្សរ ឬបោះពុម្ពតាមទម្រង់សិល្បៈក្តី ឬតាមការជ្រើសរើស ដោយមធ្យោបាយផ្សព្វផ្សាយដទៃទៀតក្តី។

៤. ការប្រើប្រាស់សិទ្ធិដែលចែងក្នុងកថាខណ្ឌ២ នៃមាត្រានេះ តម្រូវឲ្យមានករណីយកិច្ច និងការទទួលខុសត្រូវពិសេស។ ដូច្នេះ ការប្រើប្រាស់សិទ្ធិនេះ អាចមានការរិតត្បិតមួយចំនួន ប៉ុន្តែការរិតត្បិតទាំងនេះ ត្រូវតែជាការរិតត្បិតដូចមានចែងដោយច្បាប់ និងដែលចាំបាច់តែប៉ុណ្ណោះ ដើម្បី៖

ក. គោរពសិទ្ធិ ឬកិត្តិស័ព្ទរបស់អ្នកដទៃ។

ខ. ការពារសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ ឬការពារសុខភាព ឬសីលធម៌សាធារណៈ។

## ៦- សេចក្តីសម្រេចពាក់ព័ន្ធទាំងឡាយរបស់គណៈកម្មាធិការសិទ្ធិមនុស្ស (ICCPR)

រឿងក្តីរវាង Aduayom និងអ្នកដទៃទៀត ជាមួយប្រទេសTogo បណ្តឹងលេខ៤២២-៤២៤/១៩៩០ ដែលគណៈកម្មាធិការ បានសង្កេតឃើញថា " សេរីភាពទទួលព័ត៌មាន និងសេរីភាពនៃការបញ្ចេញមតិ គឺជាសសរគ្រឹះនៅក្នុងសង្គមប្រជាធិបតេយ្យ និងសេរី។ តាមខ្លឹមសារនៃសង្គមប្រជាធិបតេយ្យបែបនេះ ប្រជាពលរដ្ឋរបស់ខ្លួនត្រូវបានអនុញ្ញាតឲ្យស្វែងរកព័ត៌មានអំពីជំរើសផ្សេងៗចំពោះប្រព័ន្ធនយោបាយ/គណបក្សនយោបាយកាន់អំណាច ហើយពួកគេ អាចរិះ

គន់ ឬវាយតំលៃរដ្ឋាភិបាលរបស់ខ្លួន ដោយចំហ និងជាសាធារណៈ ដោយគ្មានការភិតភ័យពីការជ្រៀតជ្រែក ឬភិតភ័យពីការដាក់ទោសទណ្ឌឡើយ ក្នុងដែនកំណត់ដែលមានចែងក្នុងមាត្រា១៩ កថាខ័ណ្ឌ៣ ″។

**៧- សេចក្តីថ្លែងហេតុ** នៃសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីការប្រឆាំងនឹងការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ និងបន្ថោកបន្ទាប។